# ការសម្ភាសរបស់អ្នកមីង ឡុង សុជាតិ

ក៖ អ្នកដែរសម្ភាសឈ្មោះ ញ៉ែម លាភី ខ៖ អ្នកដែលត្រូវគេសម្ភាសឈ្មោះឡុង សុជាតិ

អ្នកមីង ឡុង សុជាតិ គាត់បានសិក្សាបានថ្នាក់ខ្ពស់ដែរប៉ុន្តែដោយសារប្រលងកៅអីមិនជាប់គាត់ក៏បានបញ្ចប់ការសិក្សារបស់គាត់។អ្នកមីងបានរៀបស្វាមីក្រោយហើយមានកូនទៀតហើយអ្នកមីងបានរស់នៅជាមួយនឹងក្រុមគ្រួសារហើយយើងបានក្រុមគ្រួសារមិនសូវធូរធារប៉ុន្មានទេដោយសារស្វាមីអ្នកមីងគាត់ជាអ្នកធ្វើការតែម្នាក់ហើយអ្នកមីងឈឺមិនអាចធ្វើការបានព្រោះដោយសារគ្រោះថ្នាក់ដែលអ្នកមីងជួលធ្វើឲ្យប៉ះពាល់ដល់សុខភាពរបស់គាត់ហើយឲ្យគាត់អត់បានធ្វើការងារអ្វីដើម្បីជួយដល់ក្រុមគ្រួសារឡើយពេលឥឡូវ។កាលពេលក្មេងអ្នកមីងបានធ្វើការងារជាច្រើនធ្វើអ្វីលក់ធ្វើអ្វីអ្វីជាច្រើនដើម្បីជួយដល់ក្រុមគ្រួសារហើយគាត់ព្យាយាមក្នុងការសិក្សាដោយយកភ្លើងចង្គ្រានយកមកបំភ្លឺរៀនពេលគាត់កំពុងតែរៀន
ជីវិតរបស់អ្នកមានការតស៊ូខ្លាំងណាស់ហើយឥឡូវគាត់រស់នៅជាមួយក្រុមគ្រួសារទោះថាមិនមានទ្រព្យច្រើនប៉ុន្តែគាត់មានសុភមង្គល។

ក:សូមជម្រាបសួរអ្នកមីង តើអ្នកមានមានឈ្មោះអ្វីដែរ?

ខ:ខ្ញុំឈ្មោះ ឡុង សុជាតិ។

ក:ឡុង សុជាតិ។ហើយនាងខ្ញុំឈ្មោះញ៉ែម លាភីឯការសម្ភាសន៍នេះត្រូវបានធ្វើឡើងនៅក្នុងភូមិភូមិដំណាក់សង្កែ ឃុំព្រែកកំពឹស។លោក

ខ:សង្កាត់។

ក:សង្កាត់ព្រែកកំពឹស ខណ្ឌដង្កោ រាជធានីភ្នំពេញ។ ហើយការសម្ភាសសម្ភាសន៍នៅក្នុងថ្ងៃសៅរ៍ ទី 18 2018។អ្នកមីងមានអាយុប៉ុន្មានដែរអ្នកមីង?

ខ:ខ្ញុំឆ្នាំហ្នឹងបើគិតទៅ 46 ឆ្នាំហើយ!!

ក:46!!
អញ្ចឹងអ្នកមែនដូចខាងតាំងពីអ្នកមានចាប់ដៃដៃជាមួយលោកពូរៀបការមកតើមានជួបការលំបាកអ្វីខ្លះទៅអ្នកមីង?

ខ:ពិបាកមែនទេ?ក:ចាំ!!! ខ:ពិបាកច្រើនដែរអូន!!!

ក:ចាំ!!! មីងអាយុរៀបរាប់ពីប្រវត្តិខ្លះខ្លះដែលអ្នកមីងជួបទុក្ខលំបាកនិងបានដែរឬទេអ្នកមីង?

ខ:ទុក្ខលំបាកមានកើតទុក្ខលំបាកហើយគ្រាន់តែជួបរឿងហូបចុកគ្រាន់តែវាមិនយំប៉ុន្តែគ្រាន់តែរឿងបញ្ហាក្នុងគ្រួសារវាតែងតែមានបញ្ហាៗចឹងទៅណាស់!!ក:ចាំចាំ!!ខ:និយាយឲ្យចំទៅពេលបញ្ហាតែពេលណាគាត់ស្រវឹងទេប្រសិនបើគាត់អត់ស្រវឹងអត់អីទេ!!!

ក:ស្រវឹងដែរ!!!គាត់ឧស្សាហូបញឹកញាប់អ្នកមីង?

ខ:វាយញឹកវាញឹកដែរ វាញឹកតែម្តង!!!

ក:ពិបាកដែរ!!

ខ:ហ្នឹងហើយ។

ក:គាត់ធ្វើការអ្វីដែរអ្នកមីងឥឡូវ?

ខ:សំណង់។

ក:សំណង់!! គាត់ធ្វើការតែមួយមុខហ្នឹងទេ?

ខ:ចាំ!!!

ក:គាត់ទៅឆ្ងាយឆ្ងាយដែរឬក៏អត់អ្នកមីង?

ខ:គាត់ធ្វើជាងនៅម្តុំជិតជិតហ្នឹងដែរហ្នឹង!!!ជូនកាលព្រែកហូរទៅឥឡូវឥឡូវធ្វើព្រែកហូរ!!!

ក:គាត់ឈ្មោះអ្វីអ្នកមីង?

ខ:គាត់ឈ្មោះចាន់។

ក:ចាន់!! ត្រកូលរបស់គាត់ឈ្មោះអ្វី?

ខ:ចិន!!!

ក:ចិន ចាន់!!!គាត់អាយុប៉ុន្មានហើយអ្នកមីង?

ខ:គាត់ទើបតែ៣០ជាងហ្នឹង!!ប្អូនខ្ញុំទេ។

ក:ហ្ន៎ ៣០ឆ្នាំជាង!!ហើយសព្វថ្ងៃគាត់ធ្វើតែការងារសំណង់តែមួយមុខនោះទេ!! តើគាត់ធ្លាប់បានរៀនសូត្រអីពីមុនមកទេ?

ខ: គាត់រៀនបានថ្នាក់ទី 5។

ក:ទី 5!!!គាត់រៀននៅសាលាមួយណាទៅ?

ខ:រៀននៅសាលាវត្តកែវមុនីយើងហ្នឹង។

ក:កែវមុន្នី ហ្ន៎នៅវត្តដំណាក់សង្កែ។

ខ:វត្តដំណាក់សង្កែ!!គោករលួសយើងហ្នឹង!!

ក:ចា៎ វត្តគោករលួស!! ហើយក៏អត់មានបាត់បង់តទៅសាលាផ្សេងទេ?

ខ:មានអីណាគាត់កំព្រាឪពុកម្ដាយ ម្ដាយឪពុកគាត់ស្លាប់ចោលតាំងពីគាត់នៅតូចតូចម្ដាយឪពុកគាត់ស្លាប់ចោលតាំងពីគាត់នៅតូចតូចនោះ!!!

ក:ចា៎ចា៎!!!

ខ:បានជាគ្នាទេតើយើងរកតែ ពឹងខ្លួនពឹងដោយខ្លួនឯងអញ្ចឹងទៅណាស់!!!

ក:ចា៎ ចំណែកខ្លួនរបស់អ្នកមានផ្ទាល់វិញធ្លាប់ជួបធ្លាប់ឆ្លងកាត់រឿងអ្វីពីមុននិងទៀតតាំងពីក្មេងមកអញ្ចឹងទៅណាស់?

ខ:ខ្ញុំធ្លាប់ឆ្លងកាត់រឿងថាវាពិបាកអារឿងថាយើងវាគ្មានឪពុកគ្រប់គ្រងអញ្ចឹងទៅណាស់!!

ក:ចា៎!!!

ខ:ហើយយើងតស៊ូជាមួយម្ដាយតស៊ូលក់ដូរជាមួយម្ដាយអញ្ចឹងតាំងពីតូចតូចក្មេងក្មេងអញ្ចឹងទៅ!!!

ក:ចា៎!!!

ខ:វាគ្រាន់តែឆ្លងកាត់ប៉ុណ្ណឹង!!

ក:ចាំមីងមានមិត្តភក្តិជិតស្និទ្ធដែលធ្លាប់រៀនជាមួយគ្នាដែរឬទេ?

ខ:ធ្លាប់ប៉ុន្តែឥឡូវបែកគ្នាអស់ហើយ។

ក:បែកគ្នាអស់ហើយឥឡូវពួកគាត់នៅរស់ទេទេតើអ្នកមីងណោះ?

ខ:នៅរស់ប៉ុន្តែគ្រាន់តែថាយើងយើងឥឡូវយើងមកនៅឯណោះវាចេះតែរតាតរតាយអស់!! តាំងពីពេលជំនាន់យើងនៅរាប់អានគ្នាមិនទាន់មានទូរស័ព្ទឯណា!!

ក:ចាំ!!ហ្នឹងហើយ!!

ខ:ខ្ញុំកាលនៅរៀនបានពួកម៉ាកហ្នឹងវាផ្ទុងផ្តើមនឹងណាស់ម៉ែវាឥឡូវម៉ែវាដូចជាចៅកែហើយឥឡូវ លក់ទឹកកកនៅផ្សារដើមគរយើងហ្នឹង!!

ក:ហ្ស!!!

ខ:និងហើយពេលមុនម៉ែលក់ទូហើយក៏ចេះតែមានម៉ូយច្រើនទៅ បានមីមួយហ្នឹង ខ្ញុំថាពេលនៅរៀនបានមីមួយហ្នឹងទីតាំង!!

ក:ចាំ!

ខ:ចេះតែអោយនេះនោះហូបអញ្ចឹងទៅជូនកាលខោអាវសំពត់រៀនស្បែកជើងអាវទិញអោយអញ្ចឹងទៅណា!!!

ក:ចាំ!! ឥឡូវបាននៅជួបគ្នានៅស្គាល់ដែរឬទេអ្នកមីង?

ខ:ស្គាល់!!!

ក:នៅស្គាល់!!! ប៉ុន្តែអ្នកមីងដូចជួបដែរទេតើពេលក្រោយពេលក្រោយ?

ខ:អត់ដែលជួបសោះឥឡូវ!!

ក:ហ្ន៎ប្រសិនបើជួបគ្នា!!

ខ:តាំងពីពេលមានប្តីមកមានប្តីរាងខ្លួនមកតាំងពីខ្ញុំផ្លាស់មកនៅទីនេះមកស្វាត់ឈឹងលែងជួបចូលម្ភៃឆ្នាំហើយ!!!

ក:ហ្ន៎យូរដែរហើយនៅទីនេះ។

ខ:យូរឆ្នាំដែរហើយ។

ក:ចុះគេការបានទៅចូលរួមការដែរទេតើអ្នកមីងណោះ?

ខ:ការវាការនៅឯកោះកុងឯណោះ!!!

ក:ហ្អ៎ឆ្ងាយ។

ខ:លើកោះកុងឯនោះហ្នឹង។តែគ្រាន់តែវាប្រាប់ថាពេលការនឹងវាមិនមែនពេញចិត្តថាវាការម៉ែវាចាប់បង្ខំអញ្ចឹងទៅណាស់ ម៉ែស្រីខាងស្រីម៉ែខាងប្រុសហើយអាប្រុសបើវានិយាយឲ្យចំទៅការពេលហ្នឹងដូចវាប្រុសចឹង!!វាអត់គិតគូររឿងយកប្តីទេ!! បើអត់ចង់បានវាចង់នៅលក់អញ្ចឹងទៅសប្បាយវារៀនវាសប្បាយចឹងទៅ!!

ក:គាត់អាយុប៉ុន្មានអ្នកមីង?

ខ:គេការគេអាយុស្រុកបើខ្ញុំដែរហ្នឹង!!!

ក:ចា៎!!!

ខ:បើគិតឥឡូវវាស្រវាក់ស្របាលបានខ្ញុំដែរទេតើ!!អាយុរបស់ខ្ញុំដូចជាដំណើរដំណាលគ្នានឹងអីចឹង!!

ក:មានមិត្តភ័ក្រជិតស្និទ្ធមានតែម្នាក់ហ្នឹងទេតើអ្នកមីង?

ខ:មានពីរនាក់3 នាក់ឯណោះប៉ុន្តែគ្រាន់តែបែកគ្នាអស់ហើយ។

ក:ចា៎!!! ពួកគាត់សុទ្ធតែនៅតែអ្នកមីង?

ខ:គេគ្រាន់បានណាស់គេនៅទេតើ ប៉ុន្តែគ្រាន់តែគេគ្រាន់គ្រាន់បើជាងយើង!!!

ក:ចា៎!!! អញ្ចឹងអ្នកមីងអត់មានបំណងចង់ជួបគាត់ឬក៏អ្វីទៀតទេអ្នកមីង?

ខ:បើថាចង់វាចេះតែថាបានហើយប៉ុន្តែមិនដឹងទៅជួបនៅឯណា!!!

ក:ហ្អ៎ ភ្លេចផ្ទះភ្លេចអីភ្លេចតំបន់ប្តូរផ្ទះអ្វីអស់ហើយ!!

ខ:ហ្នឹងហើយរៀបដូរផ្ទះអស់ហើយហ្នឹង
កាលពេលជំនាន់និងយើងប្រើទូរស័ព្ទយើងចេះតែតេទៅទាក់ទងគ្នាហើយនោះ,!!

ក:ហ្នឹងហើយ!!

ខ:ហើយកាលពីជំនាន់នោះមានប្រើទូរស័ព្ទឯណាបានចេះតែឬជារឃោរឃាទៅគេទៅតាមកេរ្តិ៍ប្តីជូនកាលនៅភ្នំពេញបានតែកន្លះខែទៅកោះកុងរាប់ឆ្នាំអញ្ចឹងទៅ!!!

ក:ហ្ន៎ពិបាកដែរអញ្ចឹង,!!

ខ:ហ្នឹងហើយ!!

ក:ចុះបងប្អូនខាងគ្រួសារអ្នកមីងគាត់សុទ្ធតែនៅនៅម្តុំម្តុំហ្នឹងឬក៏ឯណា?

ខ:បងប្អូនរបស់គេនៅភូមិដំណាក់សង្កែបងប្អូនគេសឹងតែទាំងអស់!!

ក:ម៉ាអីគេ?

ខ:ម៉ាដំណាក់សង្កែភូមិដំណាក់សង្កែយើងហ្នឹង!!

ក:ហ្ន៎សុទ្ធតែបងប្អូន!!

ខ:ស្រុកកំណើតម៉ែឪគេនៅទីហ្នឹង!!

ក:ម៉ែឪគាត់ខូចតាំងពីគាត់នៅក្មេងៗ?

ខ:តាំងពីគាត់អាយុ 13 ឆ្នាំហ្ន៎!!

ក:ចា៎!!!គាត់ខូចដោយសារអ្វីអ្នកមីង?

ខ:ជំងឺ។

ក:គាត់អាយុប្រហែលប៉ុន្មានចាស់មែនទេ?

ខ:គាត់ប្រហែលជា 30 ឆ្នាំជាងហើយមើលទៅ30ឆ្នាំ 40ឆ្នាំហើយ!!

ក:ហើយខូចទាំងពីរតែម្តង?

ខ:ហ្នឹងហើយប្តីខូចមុន!!!

ក:ហ្ន៎ និយាយទៅប្រវត្តិរបស់គាត់តស៊ូខ្លាំងណាស់ដែរហ្នឹងពីព្រោះកំព្រាតាំងពីតូចហើយគាត់នៅខ្លួនឯងឬក៏មានយកចិញ្ចឹមទៅអ្នកមីង?

ខ:អត់ទេផ្ទះមានប៉ុន្តែគ្រាន់តែថាស្នាក់នៅជាមួយអ៊ុំអីអញ្ចឹងទៅណាស់នៅជាមួយអ៊ុំនៅជាមួយនិយាយអញ្ចឹងទៅដល់ពេលអត់ពីយាយទៅទៅស្នាក់នៅជាមួយអ៊ុំទៅប៉ុន្តែគ្រាន់តែថាកម្លាំងរបស់យើងចេញរកខ្លួនឯងអញ្ចឹងទៅទៅធ្វើសំណង់អោយគេទៅមួយថ្ងៃ 5000អីអញ្ចឹងទៅយកពីគេយកក្នុង 1 អាទិត្យបើកម្តងនិយាយឲ្យចំមួយរស់មួយរស់អញ្ចឹងទៅ!!!
ក:ចាំ!!!
ខ:ហើយប្អូនស្រីស្រីសុទ្ធតែនៅជាមួយគេអញ្ចឹងទៅទៅនៅកន្លែងឆាក្តៅនិងមួយខែប្រាំម៉ឺនទៅ 60.000 អញ្ចឹងទៅ!!

ក:ចាំ!! និយាយទៅប្រវត្តិអត់តស៊ូខ្លាំងណាស់ធ្វើការខ្លួនឯងតាំងពីនៅតូចតែម្តង!!

ខ:តាំងតែពីនៅតូចតាំងតែពីមុនទាន់ដឹងថាទើបតែអាយុ 13 ឆ្នាំហើយប្រឹងខ្លួនឯងអញ្ចឹងទៅធ្វើវត្តខ្ញុំតស៊ូដែរប៉ុន្តែមើលទៅវាតែនាងមិនដូចគាត់ដល់ពេលគាត់អត់មានម្តាយឪពុកតាំងតែពីអាយុ 13 ឆ្នាំខ្ញុំទើបតែអត់ម៉ែឥឡូវឥឡូវទេ!!

ក:ចាំ!! ចុះខាងគ្រួសាររបស់អ្នកមីងពេលមុនគាត់ខូចឬក៏យ៉ាងម៉េច?

ខ:ខ្ញុំលែងគ្នា។

ក:ហ្ហ៎លែងគ្នាពិបាកដែរដោយសារនៅជាមួយគ្នាមិនចុះលែងគ្នា!!!

ខ:មនុស្សស្រីយើងនៅធ្វើអ្វីកើតបើគេលែងត្រូវការប្រពន្ធកូនហើយគេត្រូវការអ្នកផ្សេងៗចឹងយើងអោយគេទៅទៅ។

ក:គាត់អត់មានយកកូនទៅដែរណាអ្នកមីង?

ខ:ខ្ញុំអត់អោយផងដាក់ឲ្យបានឲ្យគេយកតែខ្ញុំមិនឲ្យខាងគេទាមទារដែលនឹងពីព្រោះគេថាខ្សែខាងចិនគេត្រូវការកូនណាស់ហើយមួយទៀតច្បាប់គេថាកូនបងត្រូវបានឪ!!

ក:ហ្នឹងហើយ!!

ខ:ប៉ុន្តែខ្ញុំអត់អោយ។

ក:គាត់ចេះអត់ប្រកែកអត់ទៀមទារនេះដែរអ្នកខ្លះអត់បានទេត្រូវតែយកឲ្យបានណាស់!!!

ខ:ចុះវាកំពុងតែងប់ងល់ហើយអូន វាកំពុងងប់ងល់ហើយ!!

ក:ហ្នឹងហើយ!!!

ខ:វាទៅគិតអ្វីកូន!!

ក:អាណិតកូនខ្លាំងណាស់អ្នកមីង!!ហើយ ចុះគាត់មានដែលមកលេងមកអីទេអ្នកមីង?

ខ:អត់ទេ!!! កាលនៅភ្នំពេញមក ឱ្យលុយអោយកាក់អោយទឹកដោះគោកូនអញ្ចឹងទៅណាស់!!!ក:ចាំ!!!

ខ:តែតាំងពេលមកនៅទីនេះអត់ដែលទេ!!!

ក:ឥឡូវគាត់នៅរស់សព្វថ្ងៃ?

ខ:នៅទេតើ។

ក:គាត់អាយុប្រហែលប៉ុន្មាន?

ខ:ហ្វ៎គាត់បងខ្ញុំទៀតឯណោះ!!!50 ឆ្នាំជាងហើយខ្ទង់បង!!!

ក:អាយុច្រើនដែរហើយ!! ហើយគាត់សព្វថ្ងៃនៅភ្នំពេញ?

ខ:នៅភ្នំពេញ។

ក:ចុះពេលដែលមីងចាប់ផ្តើមរៀបការជាមួយគាត់ដោយសារឪពុកម្តាយរឺក៏យ៉ាងម៉េចដែរអ្នកមីង?

ខ:ខ្ញុំម៉ែអានេះដូចគេហៅថាចាស់ចាស់នំវាមិនធំជាងនាឡិ!!

ក:ចាំ!!

ខ:ដូចថាម៉ែទុកឪពុកដាក់ៗចឹងទៅយើងចេះតែតាមម៉ែឪអញ្ចឹងទៅណាស់!!

ក:ចាំ!!គាត់រៀបចំអោយ!!

ខ:ចាំ!!!

ក:ពេលហ្នឹងមានថ្លៃបណ្តាការបានប៉ុន្មានទៅអ្នកមីង?

ខ:កាំងពេលហ្នឹងប៉ុន្មានទេអូនអើយភ្លេចបាត់ហើយប៉ុន្តែគ្រាន់តែថាវា!!

ក:លុយថ្លៃដែរ!!

ខ:លុយថ្លៃដែរគ្រាន់តែយើងមួយជី 1ជីមាសត្រឹមតែ 3000 លុយខ្មែរហ្នឹង!!!កាលចេញជំនាន់និងហ្នឹង។

ក:1ជីមាស 3000។

ខ: 3000 លុយខ្មែរហ្នឹង!!!

ក:ហើយឥឡូវថ្លៃសឹងអីហើយ ហ្នឹង!!!

ខ:ឥឡូវមាស 1ជីតម្លៃរាប់រយដុល្លារឯណោះ!!

ក:ចាំ វាដូតាមសម័យកាលចឹងទៅ!!!

ខ:ហើយបើការសម័យមុន ហើយសម័យ ឥឡូវខុសគ្នាមេយហើយនិងដីណាស់ កាលពេលមុនខោអាវតែមួយកំផ្លេពីកំផ្លេច្រើនពេក!!សម័យនេះផ្លាស់រាប់កំផ្លេ!!!

ក:ចាំហ្នឹងហើយ!!!

ខ:សម័យនោះគ្រាន់តែផ្ទឹមមួយកំផ្លេ!!!សែនចង់ដៃហើយផ្ទឹមនឹងជាមួយគ្នា ហ៊ី!!ហែរជំនូនហើយនឹងកាត់សក់បានតែប៉ុណ្ណឹង!!!
ហើយសក់បានតែខ្លែបខ្មោរមួយមុខតែប៉ុណ្ណឹង បើមិនអញ្ចឹងទេមូល ពោះវៀនជ្រូកទំលាក់បានតែប៉ុណ្ណឹងស្តាយណាស់កាលពេលនៅក្រមុំសម័យនេះវិញបាន!!!

ក:មីងប្រសិនបើមានឱកាសទៅនេះទៅទៅកន្លែងគេ!!

ខ:ធ្វើក្រមុំមួយសារទៀត!!!

ក:បើមិនអញ្ចឹងអោយគេទៅថតទៅកន្លែងថតតែងខ្លួនឲ្យម្តងទៀតថតទុកណាស់!!!អត់ទេមែន ទេតើអ្នកមីងកុំអោយ!!

ខ:ចេះតែនិយាយលេងទៅណាស់!!!ហួសហើយសម័យនេះហើយ!!

ក:មានតែចង់ឃើញកូនកូនអញ្ចឹងវិញ។

ខ:មានតែចាំឃើញកូនកូនវាការិញទៅ!!

ក:ចាំ!!!កាលពីមុនគាត់រកស៊ីអ្វីដែលលោកពូអ្នកមីង ខាងគ្រួសារអ្នកមីងពីរមុននឹងណាស់??

ខ:ហ្វាំ!! គាត់ខាងអគ្គីសនី!!

ក:ចាំខាងអគ្គីសនី!!

ខ:ហ្នឹងហើយខាងវិស្វករអគ្គិសនី!!

ក:ចាំ!!!គ្រាន់បើដែរ!!

ខ:វត្តភ្នំយើងហ្នឹង!!

ក:ចាំ!!!ដោយសារឈ្លក់មួយពេល!!!

ខ:ហ្នឹងហើយ!!

ក:តែម្តាយរបស់ខ្ញុំក៏អញ្ចឹងដែរ!!!ឪពុករបស់ខ្ញុំក៏ពិបាកដែរមិនមែនស្រួលស្អីឥឡូវគាត់លែងអីហើយពីព្រោះគាត់ចាស់ចាស់ហើយបានស្រួលវិញ។

ខ:មិនថាចាស់ៗជំនាន់និងជំនាន់ឥឡូវឥឡូវនេះក៏អញ្ចឹងដែរ!!

ក:ហ្នឹងហើយ។

ខ:អោយតែខ្លាចអត់លុយឲ្យតែមានលុយ!!!

ក:ចាំហើយគាត់រៀនបានកម្រិតណាដែរអ្នកមីងលោកពូ?

ខ:មុនហេ?

ក:ចាំ!!!

ខ:មុនគាត់រៀនបានជ្រៅណាស់បានជ្រៅជាងខ្ញុំគាត់រៀនដល់បាក់ឌុប!!!

ក:ចាំ!! ជំនាន់មុនបានប៉ុណ្ណឹងប៉ុណ្ណឹងអីខ្លាំងណាស់!

ខ:គាត់បានបាក់ឌុបខ្ញុំបានតែទី 7 ទេគាត់បានបាក់ឌុប!!!!

ក:ចាំ!!ឥឡូវ ជំនាន់នេះទាល់តែគេ!!

ខ:ជំនាន់នោះគេគេខាងនោះគឺរៀងធូរធារជាងនេះណាស់!!!

ក:ចាំ!!!

ខ:ខាងនោះគេនៅឪ។

ក:គាត់អត់មានម្តាយទេ?

ខ:ប្តីមុនហោ?

ក:ចាំ!!

ខ:អត់មានម្តាយទេ។

ក:គាត់ស្លាប់អាយុច្រើនហើយអ្នកមីងមែនទេ?

ខ:ម៉ែក្មេករបស់ខ្ញុំស្លាប់ខ្ញុំអត់ទាន់ផង!!!

ក:ហ៊ឺអត់ទាន់ផង។

ខ:ឪក្មេកខ្ញុំស្លាប់បានខ្ញុំទាន់។

ក:ចាំ!!!គាត់ស្លាប់ដោយសារចាស់អ្នកមីងណោះ?

ខ:ចាស់!!!

ក:ចាស់!!បទស្លាប់អាយុបានប៉ុន្មានដែរមីង?

ខ:អាវក្មេករបស់ខ្ញុំកាលពេលគាត់ស្លាប់អាយុ 60ឆ្នាំជាង!!!

ក:តិចដែរបើម្តាយថាអ្នកមាន90 ឆ្នាំជាង!!

ខ:60 ឆ្នាំជាងហ្នឹងតាំងពីឆ្នាំ 90 ជាង(1990)ហ្នូណាស់!!!គាត់ស្លាប់តាំងពីឆ្នាំ 90 ជាង(1990)ហាំ!!!គាត់ស្លាប់92(1992)អាយុ 63ឆ្នាំណាស់!!

ក:ចាំ!!!បើមកដល់ឥឡូវច្រើនហើយ!!

ខ:ចាំ!!!

ក:គាត់កាលពីហ្នឹងក៏ធ្វើការអ្វីដែរអ្នកមីង?

ខ:ឪក្មេករបស់ខ្ញុំមែនទេ?

ក:ចាំ!!

ខ:គាត់អត់មាននេះទេពេលមុនគាត់ធ្វើការជាមួយតាសឺនសានយើងហ្នឹង ការពេលហ្នឹងពេលសង្គមទានណាស់ដល់កាលពីយើងចូលឆ្នាំ 79(1979)គាត់អត់មានធ្វើអីទេគាត់នៅតែផ្ទះកូនកូនចញ្ចឹមអញ្ចឹងទៅគាត់មានកូនធមិគាត់មាន

អ្វី ហើយគាត់មើលគេអញ្ចឹងទៅណាស់គាត់មើលអ្វីៗចឹងទៅគេចេះតែដាក់អោយគាត់ទៅគាត់អញ្ចឹងទៅ!

ក:និយាយទៅគ្រួសារខាងអ្នកមីងនេះដែរនឹងណាស់សុទ្ធតែធ្វើការខាងរដ្ឋខាងអីដូចថាខ្សែធំៗដែលអញ្ចឹងទៅណាស់!!

ខ:នឹងខ្ញុំនិយាយជំនាន់មុនគេណាស់ជំនាន់ឥឡូវនេះចប់ហើយអូនអើយ!!

ក:ចា៎ប៉ុន្តែចិត្តអីចាំមើលប្រឹងប្រឹងរង់ចាំមើលកូនក្រែងលោបានល្អរីកចំរើនអ្វី!!

ខ:ចាំមើលកូនៗបានធំវិញ មិនមែនធំទេគ្រាន់តែថាមានមុខមានមាត់បន្តិចវិញ!!

ក:ចា៎ហើយគាត់មានដែរធ្លាប់ប្រាប់ពីបញ្ហាគ្រួសារដូចថាជួបជំនាន់ពពត់អ្វីខ្លះអត់មីង?

ខ:ថាប្តីរបស់ខ្ញុំហោ?ខ:ចា៎!!ខ:គាត់ប្រាប់ថាគាត់ថាគាត់វេទនាដូចតែយើងដែរដូចតែយើងនេះដែរហ្នឹង!!!

ក:គាត់ជួបដូចថាគេធ្វើបាបអីគាត់នៅជំនាន់ប៉ុលពតដែលមែនទេ?

ខ:គាត់ធ្លាប់តែថាអ៊ីចឹងគេវៃគាត់នៅជំនាន់អាពតហ្នឹង!!!

ក:ហ្ន៎!!

ខ:បានជាគាត់គ្រាំគ្រាំធ្លាក់ខ្លួនធ្លាក់ឈាមគាត់ក្អកធ្លាក់ឈាមទាំងដុំ អាពេលសម័យយើង 90 ជាងហ្នឹង!!ធ្លាក់ឈាមបានប្រហែលជាមួយខែគាត់ស្លាប់ទៅ!!!

ក:ចា៎!!!

ខ:
ធ្លាក់ឈាមតាមមាត់ផងតាមច្រមុះផងដល់ពេលអាចង់បញ្ចប់ហ្នឹងដូចថាឈាមវាកកខ្លាំងណាស់កកខ្លាំងវាអត់ធ្លាក់មកពីស្ទះនៅទីហ្នឹងដូចខ្យល់បណ្តោយទៅគាត់គ្រាំគេវៃនោះ!!!

ក: និយាយអញ្ចឹងមីងការក្រោយប៉ុលពតឬក៏ការពេលណា?

ខ:ខ្ញុំការពេលក្រោយទេ!!!ខ្ញុំរៀបការឆ្នាំ 89 92 យើងនេះហ្នឹង!!!

ក:ហ្ន៎ហ្នឹងហើយខ្ញុំភ្លេច!!!ទើបតែការតលូវឥឡូវហ្នឹងដែលខ្ញុំច្រឡំ!!!ហើយចុះគាត់មានធ្លាប់ប្រាប់អ្វីទៀតហើយគេមានដែលដូចថាគំរាមយកទៅសម្លាប់ចោលទៅអីឬក៏អត់អ្នកមីង?

ខ:គំរាមពីគំរាមហើយជំនាន់និងគំរាមប៉ុន្តែគ្រាន់តែថាគាត់វាឆ្លាតដែរហ្នឹង!!!

ក:ចាំ
អ្នកខ្លះធ្វើជាអ្នកអត់ចេះអីដូចថាធ្វើជាមនុស្សល្ងង់ដើម្បីគ្រាន់បានរស់ណាស់!!!ខ:ចាំ!!ក:គាត់ប្រាប់ថាឆ្លាតពូកែធ្លាប់ធ្វើការអីធ្វើការអីហ្នឹង!!!

ខ:អត់រស់ទេ។

ក:ដឹងតែសម្លាប់ចោលហើយ!!!

ខ:បើយើងទៅជាមួយក្នុងចង្កោមបងប្អូនស្គាល់គ្នាគឺមិនរស់ដែរយើងប្រាប់ថាយើងមិនចេះយ៉ាងម៉េចក៏ដោយក៏វាឬការថាយើងចេះដែរថាយើងស្រណុកយើងអ្នកមានដែរហើយតែយើងស្រលាញ់យើងមានគឺវាលុតយើងហើយ។

ក:អ្នកស្គាល់គ្នាយើង?

ខ:ហ្នឹងហើយ!!
ម៉ែខ្ញុំកុំអោយគេយកទៅតាំងពីជំនាន់អាពតឯនោះនិងអ្នកស្រុកជាមួយគ្នារស់នៅជាមួយម៉ាក់របស់ខ្ញុំនៅជាមួយគ្នាប៉ុន្តែវាទៅចាក់រុកអាពតប្រធានការដ្ឋានហ្នឹងប្រធានមូលដ្ឋានហ្នឹង!!!គេថាហ៎ូនៅភ្នំពេញនៅទីនោះជំនាន់មុនធ្វើស្អីជាមួយកូនមួយឈ្នួលមួយដូចគេជំទាវហើយហ្នឹងគេធ្វើស្អីគេហើយអញ្ចឹងទៅ
ហើយចុះម៉ែរបស់ខ្ញុំធ្លាប់នៅស្រុករឿងស្ទូងដកអ្វីគាត់ម៉ាអែមរបស់គាត់!!!

ក:ចាំ!!

ខ:ដល់ពេលគេអត់មាត់គេចេះតែតាមគេចេះតែតាមបានសិនណាស់គេអោយម៉ែខ្ញុំទៅស្ទូងអោយម៉ែខ្ញុំទៅដកដកបានគេកំណត់តែមួយភ្លួន ម៉ែ របស់ខ្ញុំដកបាន 3ភ្លួន ហើយដកហើយមុនគេទៀត!!

ក:ចាំ!!

ខ:ហ៊ឺ ដល់ពេលស្ទូង!!
ហ្នឹងគាត់ប្រាប់ខ្ញុំណាស់គេស្ទូងដកស្ទូងជួលពោតគាត់ស្ទូងជួលពោតពេលស្ទូងក៏ស្ទូងជាមុំចង្ក្រានបានគាត់ស្ទូងគាត់ចេះទាំងអស់។

ក:គេធ្វើយ៉ាងម៉េចទៅអ្នកមីងខ្ញុំអត់ដែលដឹងមុំចង្ក្រាន?

ខ:មុំចង្ក្រានដូចក្បាលចង្ក្រានយើងហ្នឹងណាស់!!

ក:គេអោយស្ទូងរាងអញ្ចឹង?

ខ:គេអោយស្ទូងគេចង់ដឹងថាយើងចេះដៃរឬក៏អត់ហ្នឹងបើថាអាជូរពោតក៏យើងមិនចេះហើយ អាហ្នឹងកយើងមិនចេះ!!!

ក:ហ្ហ៎!!

ខ:គេវៃចោលងាប់បាត់ទៅហើយ !!

ក:ហ្នឹងហើយសុទ្ធតែល្បិចរបស់គេ!!!

ខ:ហ្នឹងហើយប៉ុន្តែគេអត់មាត់ គេអត់ប្រាប់យើង យកទៅវាយចោលភ្លាមគេនៅតាមដានម៉ែខ្ញុំសិនបើក្រៅពីហ្នឹងគេវៃចោលហើយ តែធ្វើនេះម្តាយរបស់ខ្ញុំចេះធ្វើនោះម៉ែខ្ញុំចេះហើយម្តាយខ្ញុំក៏និយាយលេងវិញអ្នកអ្នកខ្ញុំសុំទៅបត់ជើងបន្តិចណាស់ ទៅអ្នកទៅ ទៅមកវិញម៉ែខ្ញុំថាអ្នកអើយមិនដឹងយ៉ាងម៉េចទេខ្ញុំ!!! ចឹអ្នកចឹនោមមកសុទ្ធតែទឹក!!ចុះអ្នកណានោមមកចេញកាក!!ហើយធ្វើយ៉ាងម៉េចបានថ្នាំទៅអញ្ចឹង!!អាហ្នឹងទាល់តែដាក់ត្រួយសាវម៉ៅ !ម៉ែខ្ញុំចេះតែថាទៅឡើងទៅភ្នំបានត្រួយសាវម៉ៅមួយបានមកហើយបានអីបានអំបិល!!ឲ្យអំបិលទៅប្រហែលជា 10 គីឡូម្តាយរបស់ខ្ញុំជ្រក់!!

ក:អ្នកណាគេជាអ្នកឲ្យ?

ខ:អាពតហ្នឹងណាស់។

ក:ចំយ៉ាងម៉ិចហ៊ានឲ្យយើងបានអញ្ចឹង?

ខ:ចុះយើងវាប្រាប់ឱ្យយើងធ្វើយ៉ាងហ្នឹងធ្វើធ្វើបានធ្វើលឿនធ្វើលើសចំនួនវាទៀត ប្រាប់អាមេរិកឲ្យយើងធ្វើយើងធ្វើបានលើចំនួនវាទៀតដល់ពេលយើងរួចរាល់ហើយ។វាហើយមុខប្រជុំណាស់។ពេលប្រជុំហ្នឹងបើជឿតាមមិត្តនារីនឹងណាស់!! មិត្តនារីហ្នឹងត្រូវខ្ញុំសម្លាប់ចោលត្រូវខាត!! ស្អីគេហៅយ៉ាងម៉េចទៅអាម៉េចទេបដិវត្តន៍អាម៉េចទេគេនោះ គេថាកម្លាំងយើងនិយាយទៅថាខេត្តកម្លាំងមួយនាក់អញ្ចឹងទៅណាស់ !!

ក:ហ្នឹងហើយ។

ខ:នឹងគេចុះទៅតាមដានសិនកុំអោយខាតមិត្តនារីម្នាក់បាត់ទៅហើយ!! បានម្ដាយរបស់ខ្ញុំភ្ញាក់ភ្ញាក់ខ្លួនទេតើ!!

ក:ហើយបានហើយស្គាល់មុខអ្នកណាហោ?

ខ:ដល់ហើយថាមានរឿងអីគេ?ហ៊ី ថាដង្កូវចេញពីសាច់អាពតនិយាយអញ្ចឹងណាស់ប្រាប់ម្ដាយរបស់ខ្ញុំថាដង្កូវចេញពីសាច់។បើសិនជាកុំខ្ញុំនៅតាមដានម្នាក់ឯងសិនហោ! ខ្ញុំយកអ្នកឯងទៅសម្លាប់ចោលខាតហើយគេថាស្អីបើយើងនិយាយថាខាតកម្លាំងមួយបាត់កម្លាំងមួយអញ្ចឹងទៅណាស់!!

ក:ហ្នឹងហើយហ្នឹងហើយ !! ហើយអញ្ចឹងស្គាល់មុខគេដែរ?

ខ:បងប្អូនជីដូនមួយម៉ាក់ខ្ញុំហ្នឹង!!!

ក:ហ៊ី ហើយដល់ហើយ!!

ខ:ហើយដល់ពេលម៉ាក់ខ្ញុំសួរថាអ្នកណាគេ? គេថាដង្កូវចេញពីសាច់។

ក:ហើយដល់ពេលជួបមុខគ្នាធ្វើយ៉ាងម៉េចទៅ?

ខ:ម៉ាក់ខ្ញុំអត់មាត់ទេ!!!ធ្វើម៉េចធ្វើទៅគេធ្វើយ៉ាងម៉េចធ្វើទៅគេចង់ រាយការណ៍យ៉ាងម៉េចតែគេទៅអោយតែសំខាន់ឱ្យតែថាប្រាប់អ្វីម៉ាក់ខ្ញុំម៉ាក់របស់ខ្ញុំធ្វើហ្នឹង!!ប្រាប់ឲ្យម៉ាក់របស់ខ្ញុំធ្វើម៉ាក់របស់ខ្ញុំធ្វើបានប្រាប់មួយនឹងម៉ាក់ខ្ញុំធ្វើបាន!!ចុះគាត់កូនអ្នកស្រែអ្នកចំការដែលមិនមែនកូនអ្នកជុំទិសជំទើនឯណា!!មិនមែនមិនចេះឯណា!

ក:ហ្នឹងបើគាត់មិនចេះយ៉ាប់បណ្ដោយ!!!

ខ:ហ្ហ៎បើថាជំនាន់ដូចបងរបស់ខ្ញុំឥវ៉ាន់មកភ្នំពេញទៅស្រុកវិញឃើញដើមស្រូវថាស្មៅនិងជំនាន់និងងាប់បាត់ហើយ!!!បងរបស់ខ្ញុំអត់ស្គាល់ទេណាស់កុំថាតែបងរបស់ខ្ញុំសូម្បីតែខ្ញុំក៏អញ្ចឹងដែរទៅលេងស្រុកម្ដងៗអត់ស្គាល់ស្រូវទេថាស្មៅទេតើ!!ហើយខ្ញុំបើជំនាន់ខ្ញុំពីតូចវិញអត់ចេះហូបបាយទេអូនខ្ញុំហូបតែប័រជាមួយនំប៉័ងហើយនិងសាច់មាន់សាច់គោខ្ញុំហូប បើបាយខ្ញុំអត់ហូបទេ!!!

ក:ហើយយ៉ាងម៉េចអញ្ចឹងអ្នកមីង?

ខ:ខ្ញុំអត់ចេះទេចុះបើខ្ញុំកើតមកនៅតែជាមួយអាមេរិកាំងទេបារាំងអាមេរិកាំងត្រូវគ្នាជាមួយខ្ញុំណាស់ខ្ញុំនៅជាមួយពួកវាហើយពួកវាមានស៊ីបាយឯណា!! ខ្ញុំអត់ចេះស៊ីបាយដូចជាពួកវា។

ក:យ៉ាងម៉េចនៅជាមួយពួកបារាំងពួកអីអញ្ចឹង?

ខ:វាស្រឡាញ់យើងនោះ!!
ខ្ញុំពីតូចមិនមែនអាក្រក់អ៊ីចឹងឯណាពីតូចគេហៅខ្ញុំតែមីបារាំងមីបារាំងទេតើ!!!ពូខ្ញុំឥឡូវពូខ្ញុំឥឡូវខាងប៉ារបស់ខ្ញុំសុទ្ធតែស្លាប់ហើយប៉ុន្តែនៅពោធិ៍សាត់នេះមកមានស្គាល់ខ្ញុំឯណា!!
សួរម៉ាក់ខ្ញុំថាបងមីបារាំងទៅឯណាហើយចុះមីមួយអង្គុយជិតហ្អែង!!គាត់ថាទេមិនមែនទេក្មួយរបស់ខ្ញុំមុខអាក្រក់អញ្ចឹងទេ !!
បើកសារខាងប៉ាខ្ញុំអ្នកដែលពីមុនពីមុននៅរស់និងមិនដែលស្គាល់ឈ្មោះរបស់ខ្ញុំទេហើយខ្ញុំតែខ្ញុំមីបារាំងទេ!!!

ក:ចាំ!! ហើយគេយកទៅនៅជាមួយ?

ខ:ទៅលេងផ្ទះជាប់គ្នាអញ្ចឹងហ្នឹងស្មាន
តែយើងជាប់គ្នាអញ្ចឹងហ្នឹង!!ផ្ទះពួកបារាំងនៅជួរៗចឹងទៅផ្ទះខ្ញុំជួរអញ្ចឹងអោយតែល្ងាចឡើងហៅទៅនឹងទៅស៊ីទៅជាមួយវាអញ្ចឹងទៅ!!

ក:ហើយអត់ទម្លាប់ហូបបាយ!!

ខ:ល្ងាចទៅ
ល្ងាចឡើងវាមកផ្ទះមកទឹកដោះគោអីរបស់វាអញ្ចឹងហើយស្រេចហើយវាស្រលាញ់យើងវាយកទៅលេងអញ្ចឹងនៅទីហ្នឹងទៅហើយថាវាទិញគ្រប់មុខវាទិញឲ្យចាក់វាដេរអោយទិញឲ្យគ្រប់ម៉ូត!!!មានអាវផែកខ្នងសំពត់ អៀមអីមួយកំផ្លេរ!!

ក:មីងនៅលេងជាមួយពួកគាត់ដូចថាមីងពេលហ្នឹងអាយុប៉ុន្មាន?

ខ:កាលពេលនឹងខ្ញុំនៅតូចៗណាស់!!!

ក:នៅទូចទូច!! ហើយក្រោយមកក៏បែកគ្នាកាលពេលនេះអញ្ចឹងទៅ!!

ខ:នេះ 75 ហ្នឹង(1975)!!បែកត្រឹម 75 ខ្ចាត់ខ្ចាយគ្នាអស់ទៅ!!!

ក:ខ្ចាត់ខ្ចាយអស់ពេលហ្នឹងបើសិនជានៅមកដល់ឥឡូវបែប!!

ខ:ខ្ញុំកាលពេលនៅអាពតគេអោយបាយខ្ញុំហូបខ្ញុំយំ
ណាស់!!!ខ្ញុំយំហើយប៉ារបស់ខ្ញុំអាណិតខ្ញុំណាស់1

កូនទាំងអស់មានតែខ្ញុំអត់ចេះហូបបាយ!!បានតែមាន់មួយភ្លៅប៉ុណ្ណឹងក៏ខ្ញុំរស់ដែរ!!ខ្ញុំឆ្អែតក៏ខ្ញុំអស់ចិត្តដែរ!!!

ក:អើយយ៉ាប់ដែរ!!និយាយអញ្ចឹងអ្នកមីងកាលពីជំនាន់ប៉ុលពតអាយុប៉ុន្មានអ្នកមីង?

ខ:ខ្ញុំអាយុ 6 ឆ្នាំ។

ក:នៅទូចដែរ!!ហើយចេះយើងយំចឹងយើងត្រូវការ បាយ អ្វីវាអត់ចេះធ្វើបាបដែរ?

ខ:អត់!! វាលេងជាមួយយើងទៅទៀតជួនកាលប៉ុន្តែវាដោយកន្លែងណាស់!!

ក:ចាំដោយកន្លែង!!

ក:ជួនកាលកំសៀវគេហៅខ្ញុំថាអាពៅអាពៅ !! ចាំនេះយកទឹកអោយម៉ែហ្អែងប៉ុន្តែតាមពិតក្នុងកំសៀវនិងបាយទេដាក់បាយពីក្រោមហៅសាច់មាន់ 1 ភ្លៅដឹងថាខ្ញុំអត់ចេះហូបបាយណាស់ដាក់សាច់មាន់កណ្តាលហើយដាក់ដៃឲ្យ!!!

ក: អាពតហ្នឹង?

ខ:ហ្នឹងហើយ។

ក:ចិត្តល្អម្លេះ!!

ខ:ទៅយកទៅឲ្យទៅយកតែឲ្យម៉ែទៅអូនយកទៅអោយម៉ែទៅកូនហើយយកទៅខ្ញុំដឹងថាក្នុងហ្នឹង!!មានបាយមានសាច់មាន់ខ្ញុំខ្វារបសយចេញខ្ញុំយកសាច់មាន់អង្គុយស៊ី!!!

ក:ហ៊ឺមានអាពតចិត្តល្អដែរ។

ខ:ហើយអោយតែពេលគេយកកងកុមារគេយកក្មេងក្មេងទៅដាក់មួយដុំនោះគេហៅថាកងកុមារនោះអោយតែពេលគេមកហៅក្មេងអញ្ចឹងគាត់យកខ្ញុំលាក់ហើយ !!

ក:ហ៊ឺ!!

ខ:គេហៅយាយយ៉ែម យាយយ៉ែមហ្នឹងនេះគាត់យកខ្ញុំលាក់ហើយ!! គាត់អ្នកមូលដ្ឋានចាស់គាត់មិនមែននេះគាត់អ្នកមូលដ្ឋានចាស់នាក់នៅស្រុកនិងណាស់ដល់ពេលនេះគាត់យកយើងលាក់ហើយ គាត់អ្នកមូលដ្ឋានចាស់។

ក:យ៉ាងម៉េចគេហៅថាអ្នកមូលដ្ឋានចាស់?

ខ:ពួកអ្នកស្រុកភូមិនៅទីហ្នឹង!!

ក:ហ្ហ៎!!!

ខ:ពួកយើងទៅផ្ទះហៅថាពួក 17ពួកយើងទៅពីចម្ងាយ!!

ក:ចាំ!! ហើយពួកគាត់ធ្វើការឲ្យពួកអាពតនិងដែរ!!!ប៉ុន្តែគាត់ចិត្តល្អទេ?

ខ:គាត់ចិត្តល្អជាមួយយើងទេឱ្យតែថាពេលគេមកហៅក្មេងក្មេងទៅកើបអាចម៍គោកាត់ផាងខែ ត្រឥវ៉ាន់ហ្នឹងគាត់យកខ្ញុំ លាក់ហើយ!!

ក:ហើយអញ្ជឹងអ្នកមីងនៅជំនាន់ប៉ុលពតស្រណុកណាស់អញ្ជឹង!!

ខ:ខ្ញុំអត់ដែលធ្វើអីទេពេលម្ដាយរបស់ខ្ញុំអាត្រាក់កិន ដល់ពេលម៉ែខ្ញុំអាត្រាក់កិនខ្ញុំកាប់រណ្ដៅ!! ហាបងខ្ញុំកាប់រណ្ដៅខ្ញុំកាប់រណ្ដៅគ្រាន់តែម៉ែរបស់ខ្ញុំបត់ជើង!!បងខ្ញុំគេហៅពីចល័តពីកងចល័ត វិញហើយណាស់ឲ្យកូនកូននៅជុំគ្នាឲ្យមើលមែនខ្ញុំហ្នឹង!!ខ្ញុំហ្នឹងកាប់រណ្ដៅអោយម៉ែខ្ញុំបត់ជើង ធំអញ្ជឹងទៅជើងធំជើងតូចកាប់អោយម៉ែខ្ញុំអញ្ជឹងទៅ!!
បងខ្ញុំរាល់ថ្ងៃនេះគេទៅលើកបាយពីការស៊ីនគេនោះអោយតែបាយឆ្អិនគេដាក់ថាសទុកអោយ ម៉ែខ្ញុំហើយ!

ក:ហ៊ឺប៉ះចំអ្នកស្រួលនៅ។

ខ:ចំអ្នកស្រួលប៉ុន្តែកន្លែងហ្នឹងដែលពិបាកនឹងកន្លែងនិងវេទនាណាស់អូនណាស់មុខផ្ទះចឹងហិ ក្មេងប៉ុនៗ កូនខ្ញុំកាំភ្លើង អូសអត់រួចទេណាស់វាស្ពាយអត់រួចទេវាអូនដីណាស់!!

ក:គេឲ្យស្ពាយកាំភ្លើង?

ខ:អាប៉ុនហ្នឹងប៉ុនហ្នឹងគេឱ្យស្ពាយកាំភ្លើងប៉ុនៗហ្នឹង យើងវាវ៉ៃយើងវាបាញ់យើង វាលូកអត់មាននេះទេប៉ុណ្ណឹងប៉ុណ្ណឹង!!ខ្ញុំប្រាប់ទៅហើយទៅផ្ទះម្ដាយរបស់ខ្ញុំភ្លើងអាអុសធំៗឆ្អើរ ម្ដាយរបស់ខ្ញុំនោះដាក់កំដៅគាត់ហ្នឹងហើយអ្នកជិតខាងទៅបុកទៅលួចស្រូវបានអញ្ជឹងទៅ គេបុកហើយគេយកមកដាំបាយដាំបាយនៅផ្ទះខ្ញុំហើយគេអត់ហ៊ានដាំនៅផ្ទះគេទេ!!
តែភ្លើងចង្កៀងវាអត់អោយមានផងកុំថាស្រួលតឹងខ្លាំងណាស់!!គ្រាន់តែបានមួយធូរៗពេលម្ដា យខ្ញុំអាត្រាក់កិននិងទេតើ!!ហើយគេដាំបាយអញ្ជឹងហើយទៅគេដួសអោយយើងមួយចានអញ្ជឹ ងទៅយកបាយរួចយកបាយទៅវិញអញ្ជឹងទៅ!!
ក:ចាំ!!ខ:ទៅចំងាយប្រហែលជាចម្ងាយហ្នឹងអត់ទៅដល់វត្តផង!!គុកគេនោះ!! ក:ចាំ!!

ខ:អូនអើយប៉ុនៗកូនទូចចាប់ហែកនៅណាស់!!ក:អូយ!!ខ:ខ្ញុំប្រាប់ណាស់!!ចាប់ហែកនៅណាស់!!

ក:ហែកមនុស្សរស់អីចឹងតែម្តង?

ខ:មនុស្សរស់នឹងណាស់ក្មេងក្មេងតូចតូចៗចឹងណាស់ជូនកាលវាបោះឡើងលើអាជំពុះទុងកាំភ្លើងជំពុះទុងចាំជុងអញ្ចឹងទៅ!! យើងមើលឃើញអញ្ចឹង!!

ក:អូយ ឃើញផ្ទាល់ភ្នែកខ្ញុំឃើញអញ្ចឹងមិនបាច់ទេ!!

ខ:ចុះបើផ្ទះរបស់ខ្ញុំហើយផ្ទះខ្ញុំហើយនិងគុកជាប់គ្នានឹងនៅជិតគ្នាហ្នឹង!!

ក:អូយយ៉ាប់ណាស់មើលទៅបើឃើញផ្ទាល់ភ្នែកអញ្ចឹងអញ្ចឹងអីវ៉ាន់មិនដឹងរស់នៅយ៉ាងម៉េចទេភ័យខ្លាចរាល់តែថ្ងៃតែម្តងហើយ?

ខ:ហ្នឹងហើយ!!

ក:យូរដែលអ្នកមីង 3ឆ្នាំ 8ខែនិង 20ថ្ងៃ!!

ខ:3ឆ្នាំ 8ខែ 20ថ្ងៃ ហ្នឹងហើយ!!

ក:យូរដែរ!!អូយហើយពេលបែកទៅមួយៗមិនដឹងអរយ៉ាងណាទេ!!

ខ:ហ៊ឺអរណាស់។

ក:ហើយមនុស្សឡើងព្រាតពេញដើរពេញផ្លូវពេញអីអញ្ចឹងទៅអ្នកមីង?

ខ:ពេញផ្លូវទៅ។

ក:ចែករកគ្រប់ស្រុកគ្រប់អ្វីខ្លួនឯងអញ្ចឹងទៅ!!

ខ:អាហ្នឹងរត់ទៅម៉ែរត់ដោយម៉ែកូនរត់ដោយកូនទៅនឹងណាស់ប៉ុន្តែខ្ញុំអត់ទេម៉ែរបស់ខ្ញុំកាលហ្នឹងដើរមានទាន់រួចឯណា!!គាត់នៅឈឺអាររបួសគាត់ហ្នឹង
ធ្វើរទេះឈើនោះអាកង់ម៉ែខ្ញុំអង្គុយដូចកូនតុក្កតាអញ្ចិង!!!ម៉ែរបស់ខ្ញុំគាត់នៅតែក្នុងម្លប់គាត់ធាត់គាត់ស្អាតណាស់
ហើយសក់គាត់កាត់ខ្លួនគាត់ទេកញ្ចក់មួយនឹងគាត់កាត់គេហៅថាផ្កាថ្កូរហ្នឹង!!!គាត់ក្រឡឹងកាត់ខ្លួនគាត់ហើយ!!!អត់បងប្អូនរបស់ខ្ញុំទាំងអស់អត់មានរត់ចោលម្តាយទេអូសរទេះម្តាយបែកកង់បែកកង់សុខចិត្តយកស្អីចងអាកង់យើងវាដាក់នោះយកស្អីចងនោះរុញម្តាយទៅទៀតហើយ !!

ក:ហ៊ឺ អាណិតគាត់ណាស់អ្នកមីង។

ខ:កំសត់តែពេលពូរបស់ខ្ញុំប្អូនរបស់ខ្ញុំបង្កើតនឹងគាត់មានរទេះគោ។កាក់បងរបស់ខ្ញុំកាក់សុំផ្ញើម៉ែមួយពួកខ្ញុំនៅតូចមែនប៉ុន្តែខ្ញុំសុខចិត្តខ្ញុំដែរអោយតែបានម្តាយមួយ។ប៉ុន្តែគាត់អត់ដាក់ម៉ែខ្ញុំទេណាស់!!

ក:អ្នកណាគេ?

ខ:និងប្អូនម្តាយរបស់ខ្ញុំបង្កើតតែម្តងអត់ដាក់ទេ!!

ក:គាត់ជិះអីគេអ្នកមីង?

ខ:រទេះគោហើយយើងដើរហើយយើងម្តាយយើងប្រទេសឈឺប្រទេសក្មេងៗលេងអាគេក្មេងរាល់ថ្ងៃគេរុញបណ្តើរក្មេងលេងអញ្ចឹងណាស់!!

ក:ហ្នឹងហើយ។

ខ:ប៉ុន្តែយើងឈឺណាស់!!

ក:ចាំអ្នកណាគេធ្វើអោយ?

ខ:អាពតធ្វើអោយតាហាន តាហាន តាហាន គាត់និយាយរដឹនរដឹនហ្នឹង!!

ក:គាត់ចេះបានចិត្តល្អជួយយើងដែរ!!ហៅមីងកាលពេលនៅជំនាន់ប៉ុលពតនៅជុំបងប្អូនដែរហោ?

ខ:ជុំ។

ក:គេអត់បំបែក?

ខ:បែក 1គាត់មានប្តីទៅតាមប្តីណាស់!!

ក:ចាំ!!!

ខ:ខ្ញុំនៅខាងតំបន់ 1គាត់មានប្តីគាត់ទៅខាងតំបន់ 4 បែកមកឆ្នាំ82(1982)បានជួបគ្នាវិញគាត់បែកពេលចិត្ត 76(1976)!!

ក:82(1982)បានជួបគ្នាវិញអូយសំណាងណាស់អ្នកមីងបានជួបគ្នាវិញ!!

ខ:ចុះគាត់មកស្រុកគាត់ស្គាល់ស្រុក!!

ក:ហើយ ចេះសំណាងនៅរស់បានមកជួបជុំគ្នាវិញ!

ខ:ហ្នឹងហើយគាត់បម្រុងទៅនេះទេតើកុំអីគាត់ធ្លាយទៅដល់អាមេរិកឯណោះគាត់ទៅដល់អាស្ទីអាស្ទីគេរៀងថ័ន្ទហេ!!ទៅដល់ហ្នឹងហើយឡើងឡានគេហៅទៅហើយគាត់ចុះពីលើឡានគាត់មកត្រឡប់មកវិញ!!!

ក:គាត់នឹកបងបអូនស្រណោះ!!

ខ:ហ្នឹងហើយ។

ក:ដូចថាទៅមិនរួច។

ខ:លឺគេថាម៉ែហ្អែងបងហ្អែងប្អូនហ្អែងងាប់អស់ហើយ ហៅគេមកបង្ហាញកន្លែងផ្នូរទៀត!!

ក:ហ៊ីមានអាអ្នកមកកុហាក់ទៀត!!

ខ;ហ្នឹងហើយដល់ពេលទៅគាត់ឡើងទៅហើយគាត់ដាច់ចិត្តឡើងទៅហើយនឹកឃើញយ៉ាងម៉េចទេគាត់ចុះពីលើឡានគេមកវិញកុំអីទៅដល់អាមេរិកហើយ!! ចុះពីលើឡានហើយដល់ពេល 80 ជាងគាត់ស៊ើបស៊ើបដំណឹងអញ្ជើញទៅណាស់ !! ស៊ើបដំណឹងថានៅរស់ដែលអត់លើរស់អត់ចេះតែទើបស៊ើបទៅឮឮសួររហៀងរហៀងគាត់មកស្រុកមកមកជួបទៅ!!

ក:ចេះសំណាងជួបគ្នាវិញ!!!បងប្អូន!

ខ:ជួបទៅលេងបែកគ្នាតាំងពីពេលនោះមក គាត់លែងប្ដីណាស់!!!

ក:ចា៎!!

ខ:លែងប្ដីគាត់បុណ្យលោកតាភ្នំប្ដីពូកែណាស់អ្វូននៅបាត់ដំបងពូកែណាស់ស័កសិទ្ធណាស់!!

ក:ហ្នឹងហើយអ្នកជំនឿខាងហ្នឹងគេជឿហើយ!!

ខ:ហ្នឹងហើយហើយអាប្អូនរបស់ខ្ញុំខុសមាត់ទេតើ!!!កុំអីអត់ទាន់នេះទេមិនមែនទាន់យើងមិនទាន់ដល់ថ្នាក់អត់បាយហូបឯណាបងខ្ញុំទីពីរនេះគាត់ខឹងហើយយើងនៅទីហ្នឹងខ្លាចគេយកបងបងទៅកងចល័ត ម៉ែខ្ញុំខ្លាចគេយកកូនទៅនោះខំថាអាប្អូនរបស់ខ្ញុំកូនបងទេ!! ភរគេណាស់!!
ក:ចា៎!! ខ:តាមពិតគាត់នៅក្រមុំទេ

ភរថាកូននោះដល់ហើយទៅបងខ្ញុំមកហើយវាចេះទៀតណាស់បងខ្ញុំមកហៅម៉ាក់នាង ម៉ាក់នាង ម៉ាក់នាងមកហើយមែនទេ?ម៉ាក់មកហើយមែនទេវាសួរថាអញ្ចឹងតាមពិតបងទេ!!

ក:ហើយយ៉ាងម៉េចចាំបាច់ភរអញ្ចឹង???

ខ:តែមិនអាចចឹងគេបញ្ជូនយកទៅឆ្ងាយបែកបងប្អូនបែកម៉ែបើយើងមានប្តីមានកូនមេម៉ាយគេហៅវែកណ្តាលគេឲ្យយើងនៅក្នុងភូមិនិង!!!

ក:យើងចេះដឹងកុហក់ទាន់ហេ?

ខ:ហ្នឹងហើយ!!!

ក:បើសិនជាអត់កុហក!!

ខ:ហើយអាប្អូនខ្ញុំចេះណាស់វាហៅថាម៉ាក់នាងម៉ាក់នាងមកហើយម៉ាក់ នាងម៉ាក់នាងមានបានខ្យងអត់?ខ្យងហ្ន៎!!!បានខ្យងនៅតាមឬក៏អត់?ខ្យង ក្តាមហ្នឹង!!!

ក:អើយអាណិតណាស់!!

ខ:ដល់ពេលបងខ្ញុំមកវាស៊ីបាយស៊ីបាយអាហ្នឹងគេហៅភ្នំតាចុក ស៊ីបាយបងមួយមកស៊ីបាយអ្នកណាគេស៊ីៗ ហ្អែងស៊ីៗម្លេះអាចុកក្អួត!!! គេប្រកាន់ហើយអាអូនខ្ញុំអត់ស៊ីបាយហៅស៊ីបាយអត់ !!! ពៅអត់ញាំបាយទេ!! ប៉ុន្តែនឹងនិយាយស្ទាត់គេអត់ដើរសើបទេណានិយាយថាគ្រួសាររបស់យើង!!!ពៅអត់ញាំបាយទេជីណាពៅខ្លាចចកុកក្អួតណាស់។

ក:ជីណាពៅយ៉ាងម៉េចអ្នកមីង?

ខ:ស៊ីណាពៅ គេឈ្មោះស៊ីណា ហៅស៊ីណាពៅ!!!

ក:ស៊ីណាពៅ!!!

ខ:ហ្នឹងហើយ !! ស៊ីណាពៅអត់ញាំបាយទេណាស់ម៉ាក់ណាស់!!!ស៊ីណាពៅឈប់ញាំបាយហើយ តែស៊ីណាទៅញាំបាយខ្លាចចុកក្អួតណាស់!!!ខ្លាចចុកក្អួត!!!បងរបស់ខ្ញុំជេរអាចុកក្អួតនោះ!!!

ក:ចា៎!!អាយុប៉ុន្មានពេលនេះនឹង?

ខ:បីឆ្នាំបួនឆ្នាំវានិយាយនៅប៉ែឡាំៗ!!និយាយមិនទាន់បានច្បាស់ឯណា!!

ក:ចាំអូនឈឺចាប់ណាស់អ្នកមីង!!

ក:ងាប់ងាប់និងដាច់បាយប្អូនរបស់ខ្ញុំណាស់ងាប់និងដាច់បាយមិនថាគេបង្អត់និយាយនិយាយទៅមិនមែនថាគេបង្អត់អត់មានបាយហូបបាយមានប៉ុន្តែវាថាវាបង្អត់ខ្លួនវាតែម្តង!!គេប្រកាន់មិនអោយស៊ីតែម្តង!!

ក:ហ្នឹងហើយអាណិតណាស់អ្នកមីងនៅឥឡូវអាយុច្រើនដែរហ្នឹង!!

ខ:ឥឡូវអាយុច្រើនឆ្នាំជូតអូន៣០ឆ្នាំ៤០ឆ្នាំហើយណាស់។

ក:ចាំ!! អើយដល់ហើយជួបរឿងរ៉ាវដល់កហើយម៉េចខ្លះទៅលោក!! និយាយទៅទាំងខាងមីងគ្រាន់បើតែពេលមុនជំនាន់ប៉ុលពតគ្រួសារដល់ពេលក្រោយមកទៅដោយសារនេះចឹងយ៉ាប់ទាំងអស់!!!ដូចថាវាផ្លាស់ប្តូរអស់រលីងទៅតែម្តងអីចឹងទៅណាស់!!!ចុះមីងធ្លាប់ជួបរឿងរ៉ាវអ្វីខ្លះទៀតអត់អ្នកមីង?

ខ:រឿងរ៉ាវជូរចត់មានតែអញ្ចឹងអូនមានតែអញ្ចឹងមានតែអញ្ចឹងមានតែរឿងនេះហ្នឹង!!

ក:ចាំប៉ុន្តែសំណាងចេះបានជួបបងប្អូនវិញឥឡូវគាត់នៅរស់ទេតើអ្នកមីងហី?

ខ:នៅ60 ឆ្នាំជាងហើយចង់និយាយថាគាត់ 60ឆ្នាំហ្នឹង!!

ក:គាត់នៅម្តុំណាវិញទៅមីង?

ខ:នៅម្តុំសាលាជ័យជំនះជ័យជំនះលូទឹកស្អុយនៅភ្នំពេញយើងនឹង!!

ក:ចាំអាយុច្រើនណាស់ដែរហើយគាត់!!

ខ:តែគ្រាន់តែថាគាត់បានរាល់ថ្ងៃបានកូនអាបងនោះមានជ្រោងអាហ្នឹងអត់ទាន់មានប្រពន្ធទេ30 ឆ្នាំៗហើយអត់ទាន់មានប្រពន្ធទេអត់ទាន់មានប្រពន្ធនឹកឃើញថាជួយម្តាយសិន។

ក:បងប្អូនរបស់អ្នកមីងមានគ្រួសារហើយទាំងអស់គ្នាហើយ?

ខ:មានទាំងអស់គ្នាហើយប៉ុន្តែម៉េម៉ាយពីរប្តីមានតែពីរមានតែខ្ញុំហើយនឹងបងផ្ទះវានៅទីនោះមួយបងទេនិយាយឲ្យចំទៅមេម៉ាយទី១ មេម៉ាយ ទី២និយាយយើងនៅរស់ៗចឹងតែម្តងទៅណា!!
ក:ចាំ!!

ខ:មេម៉ាយទី 1មេម៉ាយទី 2មេម៉ាយទី 3ហើយខ្ញុំទីបួននៅមានប្តី។

ក:ចុះគ្រួសារអ្នកមីងចេះធ្វើសំណង់ហើយគាត់អាចធ្វើផ្ទះបានធ្វើអីខ្លួនឯង?

ខ:ផ្ទះហ្នឹងគាត់ធ្វើតើ!!

ក:គាត់ផ្ទះខ្លួនឯង?

ខ:ចាំ!!

ក:ចុះគ្រែនេះគាត់ធ្វើដែរ?

ខ:ហ្នឹងហើយ!!

ក:ពូកែដែរ!!!
គាត់ទៅធ្វើនៅព្រែកហូរដែរ?ខ:ធ្វើនៅព្រែកហូរធ្វើបន្ទប់ជួលគេគឺម៉ៅអញ្ចឹងទៅណាក៏អត់មានកម្មករគឺម៉ៅបានអញ្ចឹងទៅយើងមានកម្មករជាងម៉ៅខ្លួនយើងទៅដល់ពេលអត់ទៅយើងស៊ីថ្ងៃគេទៅមិនទៀងត្រូវស៊ីថ្ងៃស៊ីថ្ងៃត្រូវម៉ៅត្រូវម៉ៅ!!!

ក:ចាំ!!!ចេះតែមានជាប់រហូតដែរអ្នកមីងហោ?

ខ:ចាំ ថ្ងៃមុននោះម៉ៅរៀបរបងឲ្យគេ8 ម៉ែត្របណ្ដោយវាចូលមួយម៉ែត្រកន្លះរៀបតែមួយថ្ងៃកន្លះបាន 150។

ក:ចាំ អោយតែខំដាក់ចិត្តធ្វើវាឆាប់ហើយបើអ្នកខ្លាំងនៅលេងលេងលេងភ្លេងហាត់ទៅណាស់!!!

ខ:អត់ទេគាត់បើតាម៉ៅធ្វើហើយមិនដែលចេះអត់មានពាក្យឆ្លើយថាខាតពីមុខទេពីព្រោះគាត់មានឈ្មោះជាកូនជាងគាត់ត្រូវប្រឹងខ្លួនគាត់។

ក:ចាំគាត់ដឹងពីអ្វីដែលត្រូវធ្វើ។

ខ:ចាំ!!!តែបើថាមានលុយម៉ៅបានច្រើនគាត់ធ្វើការក៏ច្រើនដែរផឹកស៊ីក៏ច្រើន!!

ក:ខ្ញុំសង្ស័យធ្វើការជាមួយបងថ្លៃខ្ញុំទេព្រោះអីខ្ញុំមានបងថ្លៃមួយនៅព្រែកហូរនឹងគាត់ធ្វើសំណង់ដែរ!!

ខ:ផ្ទះជួលណាស់!!ធ្វើបន្ទប់ជួល!!

ក:ហ្នឹងប្រហែលពីព្រោះគាត់ដូរទីនេះដូរទីនោះដែរខ្ញុំមិនដឹងថាគាត់ធ្វើទីណាដែរអញ្ចឹងណាស់!!

ខ:ឈ្មោះអីគេ?

ក:ហ៊ី!!

ខ:ពិរោះអីពួកព្រែកហូរធ្វើច្រើនណាស់!!!!

ក:ហ្នឹងហើយ!! ឈ្មោះឡា!!

ខ:ឡា!!!!

ក:ឈ្មោះឡា។

ខ:ព្រោះអីខ្ញុំធ្វើឮឈ្មោះហ្នឹងដែរនេះ!!!

ក:ខ្ទង់ប្រហារ៣០ជាង!!

ខ:ហ្នឹង!!!ឮស្វរប្ដីខ្ញុំនិយាយឡាឡា!!!

ក:សង្ស័យមនុស្សតែមួយគ្នា។។
ពីព្រោះអីបងថ្លៃរបស់ខ្ញុំនៅព្រៃហូរជាប់ផ្ទះរបស់ខ្ញុំហ្នឹងធ្វើសំណង់ដែរ!!!

ខ:ហ្អែងនៅម្ដុំណាព្រែកហូរ?

ក:ខ្ញុំនៅម្ដុំផ្លូវចុះខាងមុខវត្តអ្នកមីង!!ចុះមុខវត្តព្រែកហូរច្រកទី១!!!យើងចុះពីខាងមុខវត្តព្រែកហូរទៅខាងស្ដាំដៃច្រកទី 1ទៅចូលក្នុងទៅ។ហ្នឹងហើយនៅម្ដុំអ្នកមីងស្គាល់គ្រូជានឬក៏អត់?

ខ:អត់ទេនៅម្ដុំហ្នឹងខ្ញុំមិនសូវស្គាល់ទេ!!

ក:អត់សូវស្គាល់ពីព្រោះពុកខ្ញុំគាត់នេះគាត់មានផ្ទះមួយទៀតនៅទំនប់អញ្ចឹងគាត់ចិញ្ចឹមគោចិញ្ចឹមអីនៅទំនប់នៅអីអញ្ចឹងណាស់!!

កូន:រោងទុកចោលមីង?

ក:រងចិត្តជីផ្លូវចិនតែម្ដងណាស់!!

កូន:មិនដឹងមួយណាទេប៉ុន្តែខ្ញុំឃើញរោងគោមួយទុកចោល។

ខ:ប្ដីខ្ញុំច្រើនតែស្គាល់ខ្ញុំមិនស្គាល់ទេ ដូចថាខ្ញុំជំនួលមកនៅទីហ្នឹងតាំងពី!!!!

ក:កូនដៃរអ្នកមីង(ឃើញក្មេងដើរមក)!!

ខ:ក្មួយ!!

ក:ក្មួយមាឌៗដល់ហើយអាយុប៉ុន្មានហើយ?

ក្មួយ:១៨!!

ក:14 ដល់កហើយ!!

ខ:ហ្អែងកុំប្រាប់គេថាអាយុ 14ហាំ!!

ក:អើយដល់ករហើយ!!!

ខ:បើ 17 ឆ្នាំ 18ឆ្នាំទំនងជាបន្តិចណោះ!!!

ក:ហ្នឹងហើយលេង១៨ឆ្នាំមើលតែ!!មាឌធំធំដល់ហើយ!!!

ខ:ចង់ម៉ែឪវាមាឌធំៗខ្ពស់ខ្ពស់ដល់ហើយមាឌបានបានណាស់!!

ក:ហើយផ្ទះនៅជិតហ្នឹងដែរ?

ខ:នេះផ្ទះនេះ។

ក:ចាំហើយម៉ាក់ប៉ានៅរស់អីធម្មតា?

ខ:នៅរស់ទេតើ!!

ក:ហើយរៀនថ្នាក់ទីប៉ុន្មានហើយ?រៀននៅសាលាណាអូន?

ក្មួយ:សាលាព្រែកកំពឹស។

ក:ព្រែកកំពឹស!!!ចុះអ្នកវិញឥឡូវអត់មានសាច់ញាតិណារស់នៅក្រៅប្រទេសអីអីទេមីងណោះ?

ខ:បែបស្លាប់បាត់ហើយបើទោះបីជាមានបើភ្លេចអាស័យដ្ឋានរបស់គាត់អស់ដែរមានមានខាងប៉ាយូរហើយយើងដឹងយូហើយប៉ុន្តែគ្រាន់តែថា!!

ក:អត់ដែលទាក់ទងគ្នាមកសោះ?

ខ:អត់ដែលទាក់ទងគ្នាពីព្រោះអីបានថាអ៊ីចឹងអាសយដ្ឋានគាត់ឲ្យមកឲ្យមកពូនៅពោធិ៍សាត់ហ្នឹងណាស់ហើយគេអោយមីងហ្នឹងគាត់ផ្ដាំមកអោយម៉ាក់ខ្ញុំមួយខែចិញ្ចឹមណាស់ហើយអោយម៉ែខ្ញុំ 1ខែ 70 ចិញ្ចឹមហើយឲ្យខ្ញុំ20 រៀលហើយឱ្យថាអោយមីបារាំង 20

រៀលទៅក្រៅពីហ្នឹងស្រេចតែឲ្យទៅណាហើយខ្ញុំហើយម៉ែខ្ញុំអត់នេះប៉ុន្តែគ្រាន់តែបានឮតែមាត់ដល់ពេលគាត់ស្រវឹងគាត់ថានេះមីនាងឯងយកអាសយដ្ឋានតេទៅអ្នកមីងរបស់ឯងទៅអ្នកមីងឯងចង់ជួបឯងដល់ពេលហើយខ្ញុំក៏យកអាសយដ្ឋានបានហើយចម្លងបានហើយយកអាស្រិនឲ្យគាត់វិញនោះតាំងពីពេលនោះមកគេតេទៅតេអត់ចូលបិទរហូតដូចថាគេមិនចង់ផ្ដល់ឲ្យយើងៗចង់ទៅណាស់អាហ្នឹងខាងប៉ាតេ។

ក:យូរឆ្នាំហើយអ្នកមីងណោះ?

ខ:យូរឆ្នាំហើយតាំងពីឆ្នាំ 90 ជាងឯណោះ!!

ក:ហ្ហូតាំងពីឆ្នាំ 90 ជាង!!

ខ:ខ្ញុំមិនមែនចេះតែថាក៏មិនថាយើងរស់ដោយសារគេធ្វើរយើងដែរ យើងតាំងពីធំដឹងក្ដីមករស់ដោយសារកម្លាំងខ្ញុំខ្លួនខ្ញុំផ្ទាល់តែម្ដង។

ក:ចាំគាត់ត្រូវមីងអ្នកមីងណោះ?

ខ:ត្រូវជាមីងខាងប៉ា
ត្រូវជាមីងរបស់ខ្ញុំប្អូនប៉ារបស់ខ្ញុំបង្កើតនៅបារាំងប៉ុន្តែគ្រាន់តែថាខាងប៉ារបស់ខ្ញុំគេនៅពីរនាក់ដែរបីនាក់ទាំងនៅបារាំងនិងណាស់តែនៅ
2នាក់នៅស្រុកខ្មែរ!!គេបំបិទមិនឲ្យយើងទាក់ទងស្គាល់ក៏យើងតាមដំណើរអញ្ចឹងទៅ!!!

ក:ចាំហ៊ីពិបាកដែរប៉ុន្តែយើងមានអ្វីក្រៅពីខ្លួនទីពឹងខ្លួនទេអ្នកមីង។

ខ:ហ្នឹងហើយ!!
ក្មួយជីដូនមួយមួយទៀតនៅអាមេរិចណាស់ប៉ុន្តែគ្រាន់តែថាក៏យើងមិនដែលទំនាក់ទំនងគេគេមិនដែលទំនាក់ទំនងយើងគេកនេះខ្ជិល!!
តែបើថាវាមកអញ្ចឹងទៅជួនកាលធ្វើអោយម៉ែខ្ញុំអញ្ចឹងទៅណា10 ដុល្លារ
20ដុល្លារអោយអញចង់ទៅពេលជួបម៉ែខ្ញុំអោយអញ្ចឹងទៅឲ្យចាយអញ្ចឹងទៅណាស់!!!

ក:ចាំ!! ឥឡូវបាត់ឈឹងរហូតអញ្ចឹងទៅមីងហេ?

ខ:អត់ទេម៉ែរបស់គេនៅស្រុកឯណោះនិងម៉ែរបស់គេនៅដងគង
អត់ទេគ្រាន់តែថាម៉ែគេមិនមែនជាក្មួយរបស់យើងបង្កើតឯណាក្មួយជាសាច់ម៉ែវាហើយនឹងខ្ញុំជា

ជីដូនមួយបង្កើត!!!ប៉ុន្តែគ្រាន់តែថាយើងគ្រាន់តែថាបានអញ្ចឹងទេណាស់យើងទៅនេះអីយើងរាល់ថ្ងៃរស់ដោយសារខ្លួនយើងទេអូនណាស់!!

ក:ចាំ!!

ខ:ពឹងអីគេ។។

ក:អ្នកមីងនៅចាំដូចថាចេះអានអក្សរខ្មែរ នៅមើលដាច់មើលអីដែរធម្មតាតើអ្នកមីង?

ខ:នៅអានដាច់ទីតាប៉ុន្តែគ្រាន់តែថាឥឡូវវារាងរីបន្តិចទាល់តែពិនិត្យបន្តិច!!!ភ្នែកវារាងស្រវាំង!!

ក:ភ្នែករាងស្រវឹងអ្នកមីង!!

ខ:ចុះយើងវានេះណាស់អូនវាគ្រោះថ្នាក់ភ្នែកត្រូវភ្នែកផងត្រូវក្បាលផងវាសព្វ។វាតារុនតារៀកុំអីខ្ញុំចូលធ្វើការរោងចក្រទេតើ!!

ក:មីងធ្លាប់មានបញ្ហាគ្រោះថ្នាក់?

ខ:ដៃរបស់ខ្ញុំ ធ្លាប់បាក់ទេតើក្បាលនេះ 8 ថ្មេរ បានខ្ញុំនៅផ្ទះកុំអីខ្ញុំមិនដែលនៅផ្ទះទេខ្ញុំទៅធ្វើការ។

ក:ដោយសារអ្វីអ្នកមីង?

ខ:បោសអារមែងភ្លើង ដល់ពេលវាវិលមុខនោះវិលមុខក៏ដួលបោកក្បាលទៅជញ្ជាំងអញ្ចែកប៉ុន្តែអ្នកដឹងមិនដល់ជញ្ជាំងឬក៏ដោយជញ្ជាំងធ្លាក់ដល់ខាងក្រោមនេះទៅហើយ!!!!

ក:ធ្លាក់ពីលើផ្ទះនិងមក?

ខ:ហ្នឹងហើយៗចឹងបានខ្ញុំនៅផ្ទះ
ខ្ញុំចេះតែថាជាក្បាលខ្ញុំអញ្ចឹងហ្គីតាកុំអីខ្ញុំមិននៅផ្ទះទេខ្ញុំទៅធ្វើការរោងចក្រតើ!!!ទៅរាល់ឆ្នាំរាល់ថ្ងៃហ្នឹង!

ក:អត់ដែលថតមើលថតអីទេមីងណោះ?

ខ:អត់ដែលថតទេអត់លុយនិយាយត្រង់គឺអត់លុយបើគេថតសុទ្ធតែ $100 ជាងហើយយើងប្តីរកស៊ីតែម្នាក់ឯងយើងទៅរកឯណាអូនអើយ!!

ក:ហ៊ីយ៉ាប់តែម្តងអ្នកមីង!!
វាគ្រោះថ្នាក់មើលមិនឃើញទាល់តែប្រញាប់ប្រយ័ត្នប្រយែងខ្លាំងណាស់។អ្នកមីងចេះភាសាផ្សេងក្រៅពីភាសាខ្មែរដែរឬក៏អត់?

ខ:ភ្លេចអស់ហើយអូនអើយ។

ក:តែធ្លាប់រៀនដែរអ្នកមីងណោះ?

ខ:ធ្លាប់រៀនដែរប៉ុន្តែទាស់តែភ្លេចប៉ុន្តែជំនាន់ខ្ញុំរៀនអត់មានអង់គ្លេសទេខ្ញុំរៀនបារាំងតើវាចូលត្រឡោកឥឡូវហើយនោះប៉ុន្តែគ្រាន់តែថាបើគេនិយាយមកជូនកាលស្តាប់បានតែនិយាយទៅវិញអត់កើត!!ដូចវារឹងមាត់ខាននិយាយយូរឆ្នាំ អញ្ចឹងទៅណាស់!!

ក:ចាំខាននិយាយយូរឆ្នាំប៉ុន្តែនៅស្តាប់ដឹងថាគេនិយាយអ្វី?

ខ:ស្តាប់បានគ្រាន់តែដឹងថាគេនិយាយបានខ្លះប៉ុន្តែគ្រាន់តែថាយើងនិយាយទៅវិញនិយាយអត់កើតមិនដឹងថាយ៉ាងម៉េចការឲ្យដឹងគឺយល់
ចុះយើងតាំងពីយើងក្រមុំនោះខ្ញុំរៀនបារាំងប៉ុន្តែគ្រាន់តែលើកូនរបស់ខ្ញុំបងនោះជិត 30 ឆ្នាំហើយយើងបានរៀនគិតទៅ20 ឆ្នាំជាងទៅហើយ!!!ម្លោះហើយវាចូលត្រឡោកខ្លះហើយ!!

ក:ហ្នឹងហើយ។

ខ:អាហ្នឹងយើងនិយាយភាសាសាមញ្ញថាវាចូលត្រឡោកហើយនឹងណាស់ប៉ុន្តែបើខ្មែរអាចបានសរសេរបានអីបានវាច្បាស់ជាងសាសហ្នឹងអង់គ្លេសហើយនិងបារាំងនិង!!សរសេរបានច្បាស់!!

ក:បើដូចហើយបារាំងគេនិយាយមកយើងស្តាប់បានអញ្ចឹងទៅ!!ចង់មីងរាល់ថ្ងៃនៅតែផ្ទះទេថាអត់មានធ្វើការងារផ្សេងៗទៀតទេ?

ខ:អត់ទេអូននៅតែកំប៉ែកុំប៉ុកនៅផ្ទះធ្វើបើរោគប្រចាំកាយអញ្ចឹងហ្នឹង វាអត់មានរោគអីទេតែក្បាលហើយនឹងដៃហ្នឹង!!!ជើងនេះប្រេះហើយហាំ!!

ក:អូយ!!

ខ: អាជើងនេះក៏ប្រេះដៃនេះក៏បាក់អាក្បាលនេះក៏បែក។

ក:ប៉ុន្មានឆ្នាំហើយអ្នកមីង?

ខ:ពីឆ្នាំបីឆ្នាំហើយ!!

ក:ទើបតែឥឡូវឥឡូវហ្នឹងដែរ។

ខ:បើក្បាលទើបតែប្រហែលមួយឆ្នាំទេដៃនេះបែកបាក់នេះមិនទាន់បានមួយនេះផងក្បាល ដៃមិនទាន់បាននេះផងជើង ជើងមិនទាន់បានស្រួលផង មកក្បាល។

ក:ដោយសារវិលមុខ?ពិបាកដល់ហើយវាដូចទាល់តែយើងប្រយ័ត្នប្រយែងខ្លាំងណាស់អ្នកមីង ហើយមីងអត់លើសឈាមអត់លើសអីទេ?

ខ:អត់។

ក:ចឹបានស្រវាំងភ្នែកអ្នកមីង?

ខ:យើងផ្កាសាយនោះ!!យើងវាចង់ផ្កាសាយដល់ពេលធ្វើយើងចង់បង្ហើយមួយទៀតដាក់ដាំបាយទៅកូនរកកោសខ្យល់ពេលប៉ារបស់ឯងមករក
កោសខ្យល់អោយបន្តិចនឹកឃើញអញ្ចឹងណាស់!!!

ក:ចាំ!!

ខ:ក៏បោសហើយអញ្ចឹងទៅក៏ងើបឡើងវារាងដូចស៊េរមួយភ្លែតៗចឹងណាស់។

ក:ហ្នឹងហើយ។

ខ:ស៊េរៗជញ្ជាំងជញ្ជាំង កៀនទីហ្នឹងនេះ!!គោងមិនដឹងដល់ជញ្ជាំងឬក៏មិនដល់ស្រាប់តែដល់ក្រោមឯណោះទៅហើយហ្នឹង !! នៅក្រោមឈាមអត់ដឹងថាឈាមក្បាលទៅទៀត វាឈឺទីនេះខ្លាំងថ្មីៗចឹងបានពេទ្យថាអញ្ចេក វាចំអាជើងគោនិងយើងចេះបានឈាមណាស់ទី 1 បាន ឈាមហូរទី 2 យើងអត់លើសឈាម!!!

ក:ហ្នឹងហើយចាំ!!

ខ:បើសិនជាយើងអត់ឈាមហូរហើយទោះបីជាយើងអត់លើសឈាមក៏ដោយបើឈាមអត់ហូបខ្ញុំទៅតាំងពីថ្ងៃហ្នឹងនោះ!!!ប៉ោងអូនពីក្រោយទីហ្នឹងប៉ោងតែម្តងណាស់ប៉ុន្តែយើងបានក្បាលនេះ វាបានឈាម8 ថ្នេរ។

ក:ហ្នឹងហើយខ្ញុំលឺគេថាបើសិនជាដួលមកអត់ឈាម!!

ខ:បើដួលមកអត់ឈាមទៅតាំងពីថ្ងៃហ្នឹងនោះ!!!បើយើងលើសឈាមក៏ទៅដែរ!!

ក:វាកកនៅទីនោះតែម្តង។

ខ:តែគ្រាន់ថាយើងចេះសំណាងបានឈាមដល់ពេលខ្ញុំទេអាហ្នឹងខ្ញុំស្អំអានេះណាស់ពេលឲ្យស្អំណាស់អូនឡើងក្រហាយតែម្តងបែបវារលាយឈាមមិនដឹងអីមិនដឹងក្រហាយយកតែម្តងណាស់។

ក:ស្អំទឹកកកឬក៏ស្អំទឹកក្តៅអ្នកមីង?

ខ:ផ្សំទឹកកកពេទ្យឲ្យស្អំទឹកកកហើយខ្លះគេថាអោយស្អំទឹកកកទៅណាស់ស្អំនៅទីហ្នឹងឡើងក្រហាយតែម្តងហើយយើងវែកមើលអោយប៉ារបស់វាអោយកូនវែកមើលកន្លែងយើងក្រហាយអត់មានឃើញស្នាមទេអត់មានឃើញស្នាមរយ៉ាស់ឬក៏ឆ្មួតអីអត់ទេ!!!តែឡើងក្រហាយតែម្តង!!

ក:ហើយដេរប៉ុន្មានថ្នេរទៅអ្នកមីង?

ខ:8។

ក:ហ្វ៎វែង។

ខ:បានម៉ែអានេះទេតើ!!

ក:ឃើញទាន់អ្នកមីងហេ?

ខ:ឃើញកូនវាទៅប្រាប់
ឃើញឈាមវាមានហ៊ានឯណាហូម៉ាក់ឈាមម៉ាក់ឈាមវាក៏ទៅប្រាប់ម៉ែវានេះហើយគ្នាកូនខ្ចីទៀតហើយកូនខ្ចីម៉ែវាមកមានតែទៅប្តីឯណាប្តីយើងឯណាតេទៅប៉ារបស់វាអានេះ!!

ក:ឃើញមិនដឹងស្លុតយ៉ាងណាទេ!!

ខ:បានប៉ារបស់វាមកតេទៅប្រាប់ប្តីរបស់ខ្ញុំទៅមកហើយប្តីខ្ញុំថ្ងៃនិងម៉ូតូគាត់យកទៅធ្វើការទៀតជិះម៉ូតូគេទៀតដល់ពេលប្តីរបស់ខ្ញុំមកខ្ញុំនៅពេទ្យឯណោះតើវាដឹកទៅពេទ្យទេតើ!!
ទៅអាពេទ្យសង្កាត់នេះទម្រាំតែឆ្លើយបានអំបោះអត់មានអត់មានម្ទុលចង់កន្លះម៉ោងឈាមចេះតែហូរតក់ៗនិយាយពីថាអើរសមតែសក់វែងផងអូនអោយដូចឡើងកន្ទ្រើងតែម្តង។

ក:ហ្នឹងហើយ។

ខ:ហើយចុះឈាមឡើងពេញមួយក្បាលបាញ់បង្ហើបបាញ់បង្ហើបបាញ់ទាល់តែទៅពេទ្យជូនទេតើ!!!ដេរនៅពេទ្យជូនអស់
30រពេលពេទ្យជូនចាប់មួយដេរមួយចាប់មួយដេរមួយហើយអោយប៉ាវាជួយទុកកន្លែងបិទមុខរ

ប្ដូសនិងណាស់!!!!ហើយខ្ញុំសួរទៅពេទ្យជូនថាខ្ញុំនៅតែឈឺចាប់ឈឺចាប់ហើយគាត់ថាយើងសរសៃឈាមវាធម្មតាគឺអញ្ចឹង!!!

ក:ហ្នឹងហើយ។

ខ:ព្រោះយើងវាអញ្ចឹងវាដាច់សរសៃឈាមដល់ដាច់សសៃឈាមយើងដេកជិតវិញសរសៃឈាមវាមិនរលូនមុខជាមួយគ្នាវិញឯណា!!!

ក:ហ្នឹងហើយ។

ខ:អញ្ចឹងចរន្តឈាមវាថាអត់នេះទេអញ្ចឹងវាចាក់ៗហើយ!!

ក:ចាំ!!!

ខ:អញ្ចឹងវាមានតាមដំណើរនឹងទៅហើយមានអ្នកបំភ័យយើងទៀតណាស់អាៗចឹងហើយឲ្យឈឺហើយញញឹមស្ពំទឹកកកឧស្សាហ៍ស្អំទឹកកកបានតែមួយអាទិត្យងាប់ហើយ!!

ក:ចំ មានអ្នកនិយាយអញ្ចឹងទៀត!!

ខ:បើងាប់តាមដំណើរទៅអញ្ចឹងតាមដំណើរទៅអាយុយើងអស់ត្រឹមណាទៅត្រឹមហ្នឹងទៅ!!

ក:មានអ្នកបន្ថែមល្បោយអញ្ចឹងទៀត!!!

ខ:ថាគេនោះ 4ឆ្នាំ 5
ឆ្នាំហើយស្រាប់តែពេលចេះតែឈឺក្បាលស្អំទឹកកកមានអ្វីបានតែមួយអាទិត្យ!!
ខ្ញុំថាប្អូននេះគាត់និយាយហ្ន៎!!
ហើយបើមីងមួយនោះគាត់និយាយគាត់ថាវាគ្រោះថ្នាក់ចរាចរប៉ុន្តែវាផុងលលាណាស់
ដល់វាផុងលលាដ៏គេដូរលលាដ៍យ៉ាងម៉េចទេ!!ដល់ពេលវាជាប្រហែលបានតែ 2
ឆ្នាំពីឆ្នាំចាប់ផ្តើមឈឺក្បាលឈឺក្បាលដូចជាវាស្រាវស្រាញ់ !!
ក:ចាំ!!!ខ:បានតែមួយអាទិត្យវាក្រុងសែរអាហ្នឹង។

ក:ហ៊ើចេះសំណាងអត់លើសឈាមអត់លើសអ្វីចេះបាននៅរស់រានមានជីវិត!!!

កូន:នៅពោចិនតុងឡានកិនក្បាល ប្រេះឬរលាយកទៅពេទ្យវៀតណាមមើលឡើង 3 4 ម៉ឺន ម៉ែឪលក់ផ្ទះមើលកូន!!!ដល់ពេលជាក្បាលឡើងករពិក្រពើកៗ!!!

ក:ហ៊ើ ចេះនៅរស់ដែរ??

កូនៈនៅរស់ទៅពេទ្យវៀតណាម
កូនអ្នកមានគុណណាស់រៀននៅបែលធីម៉ែឪអ្នកមានហើយលក់ផ្ទះនាំកូនទៅមើលនៅវៀតណាម។

ខៈខ្ញុំក៏អញ្ចឹងដែរមើលក្បាលមើលអស់ច្រើនណាស់។

កៈចាំ!!មានតែព្យាយាមដូចថារកកន្លែងអ្វីដែលសប្បាយសប្បាយកុំគិតច្រើនកុំខ្វល់អីច្រើន!!

ខៈដល់ពេលមកត្រឹមម៉ែនេះ អូនថាបងឯងទប់អារម្មណ៍ខ្លះទៅតែរឿងគាត់អញ្ចឹងគាត់ទុំជ្រុះហើយបងឯងកុំគិតច្រើនពេក។

កៈហ្នឹងហើយ!!

ខៈអូនខ្ញុំទើបបានបាយពេលល្ងាចមិញមកព្រឹកមិញបានបន្តិចបន្តិចតាំងពីម៉ែខ្ញុំស្លាប់មកខ្ញុំអត់បានហូបបាយទេណាស់អត់ហៅទេ!!!

កៈមីងធ្វើអញ្ចឹងធ្វើបាប មិនមែនធ្វើបាបខ្លួនឯងទេធ្វើបាបទាំងកូនរបស់អ្នកមីងទៀតនោះ!!!

ខៈអូនលេបមិនរួចតែម្តងលេបមិនរួចតែម្តងណាស់ប្រឹងលេបដល់ពេល ប្រឹងខ្លាំងធ្វើស្មារទោសប្រឹងខ្លាំងទុកបុករកតែក្អួត!!!

កៈមីងកូនសុទ្ធតែនៅរៀនទេតើណោះ?

ខៈរៀន 2។

កៈចាំរៀនពីនាក់ ហើយរៀនថ្នាក់ទីប៉ុន្មានហើយនោះ?

ខៈអាគោកម៉កនឹងមែនទេ?រៀនបាន ទី5 ហើយប៉ុន្តែឪវាអោបទុករៀនបានតែទី៣ទេ!!!នាយកនិងគ្រូមកសួរខ្ញុំថាបងឯងចេះតែអញ្ចឹង!!! ខ្ញុំថានឹកឃើញចេះតែតាមហ្នឹងទៅតាមដំណើរហ្អែងចេះមិនចេះតាមដំណើរបើគ្រូអោយឡើងគ្រូឲ្យឡើងទៅទៅ!!

កៈនៅជិតនឹងនៅរៀនជិតហ្នឹងតើអ្នកមីង?

ខៈវារៀននៅសាលាយើងហ្នឹង!!

កៈចាំចុះអ្នកវិញស្រែចម្ការអ្នកមីងអត់ធ្លាប់ធ្វើទេណោះ?

ខ:ខ្ញុំហោ?

ក:ចាំ!!!

ខ:អត់មានស្រែធ្វើផង។

ក:ដូចថាពីមុនអី!!!!

ខ:ពីមុនធ្លាប់។

ក:ធ្លាប់ធ្វើហើយមីងចេះដូចថាចូលចិត្តចំរៀងអីអត់?

ខ:ចូលចិត្តដែរប៉ុន្តែទាល់តែបទអារឿងអាអីឥឡូវដូចស្អីឥឡូវមិនសូវប៉ុន្មានទេប៉ុន្តែពេលមុនពេលមុនខ្ញុំរៀងចំណូលដែរចម្រៀង!!!

ក:ចាំ មីងដែរចេះច្រៀងខ្លួនឯងទេឥឡូវ?

ខ:ច្រៀងលេងច្រៀងបាន!!!

ក:អត់ហ៊ានអោយអ្នកមីងច្រៀងទៀតណាស់!!!

ខ:អៀនមាត់!!

ក:ចុះអ្នកមីងអត់ថតធ្វើអ្វីផ្សេងក្រៅពីហ្នឹងអ្វីការងារ?

ខ:ធ្វើការអូនការងាររោងចក្រ។

ក:ចាំ ធ្វើការធ្វើការបានប៉ុន្មានឆ្នាំដែរអ្នកមីង?

ខ:បានប៉ុន្មានឆ្នាំហើយ 2 ឆ្នាំទៅ 3 ឆ្នាំហើយប៉ុន្តែទើបតែជួបពេលខ្ញុំឈឺដៃហ្នឹង!!!

ក:ចាំ!!!ទើបតែឈប់ឥឡូវ។

ខ:នៅពីតូច ពីតូចមិនបានធ្វើបានប៉ុន្មានទេ!!!

ក:ចុះអ្នកវិញចូលចិត្តម្ហូបអ្វីជាងគេទៅ?

ខ:ផ្ទះខ្ញុំប្រចាំការតែម្តងគឺម្ជូរ!!!

ក:ចាំ!!!

ខ:ហើយនិងត្រីអាំង។

ក:ចាំត្រីអាំង!!!ពេលប្តីយើងស្រវឹងទៅយើងស្លសម្លកស្លរប្រហើរបានអញ្ចឹងដាក់ម្ជូរទៅ!!!ខ្ញុំម្ជូរហ្មបបានតែម្តងអូន ជាពិសេសម្ជូរត្រពាំងជូរ។

ក:ចូលចិត្តអាហ្នឹង?ខ:ហ្នឹងហើយបើម្ជូរត្រពាំងជូរជាមួយត្រីប្រាហ្នឹងហើយផ្ទះខ្ញុំបាយត្រូវ 2
កំប៉ុងត្រូវដាក់ 3 កំប៉ុងទៅ!!!

ក:ហ្នំចំណូលផ្សេងគ្នាប្រសិនបើផ្ទះរបស់ខ្ញុំកម្រស្លរចឹងណាស់តែត្រពាំងជ្រក់បានបាន
ស្ងោរបង់អំបិល
អីដាក់ម្ទេសដាក់អីអាហ្នឹងចូលចិត្តហើយធ្វើជ្រក់!!ដាក់អីអញ្ចឹងទៅណាហើយនឹងត្រពាំងស្រស់
!!!ប៉ុន្តែបើហូបត្រីប្រាអត់ដែលហូបទេ!!!

ខ:ខ្ញុំត្រពាំងស្រស់អត់សូវប៉ុន្មានទេជាពិសេសបើប្តីរបស់ខ្ញុំទឹកគ្រឿងខុសពីត្រីប្រាអត់ហូបទេ
មិនមែនថាអត់ហូបទេហូបប៉ុន្តែរអ៊ូ!!អត់មានជាតិខ្លាញ់!!

ក:ហ៊ីគាត់ចូលចិត្តខ្លាញ់!!!

ខ:ព្រោះត្រីប្រាមានជាតិជាងគាត់ថាមិនព្រមធ្វើត្រីប្រាត្រីប្រាមានជាតិជាង គាត់រអ៊ូអញ្ចឹង!!!

ក:តែរករឿងអ្វីគាត់មិនដែលដែរ?

ខ:អត់ដែលទេ។

ក:អត់អីទេ !!!

ខ:អោយតែមកពីធ្វើការបាយមិន ឆ្អិន១១១ម្ហូប មិនឆ្អិនអោយតែឃើញនៅផ្ទះ!!

ក:ហ្នំមើលទៅគាត់!!

ខ:គាត់មិនចង់ឱ្យដើរផ្ទះគេអញ្ចឹងណាស់!!!

ក:គាត់ចិត្តស្រួលដែរហ្នឹងណាស់ !!!

ខ:ថ្ងៃនេះថ្ងៃសៅរ៍មិនដឹងថ្មើរមាណមកទេ!!!

ក:ចុះមីងឬក៏គ្រួសារ
អ្នកមីងមានអ្នកណាគេចេះលេងឧបករណ៍តន្ត្រីឧបករណ៍ភ្លេងខ្មែរចេះឥវ៉ាន់អីទេ?

ខ:ស្លាប់អស់ហើយអូនអើយ!!

ក:ប៉ុន្តែពេលមុនមានអ្នកចេះ?

ខ:ចេះ!!!

ក:គាត់លេងភ្លេងអីគេទៅអ្នកមីង,?

ខ:លេងភ្លេងខ្មែរបុរាណយើងហ្នឹងប៉ុន្តែគាត់ទៅអស់ហើយអ្នក
ចេះចេះហ្នំ!!!ជាពិសេសបងរបស់ខ្ញុំនេះម៉ែរបស់ស្រីនិច្ចជាមួយហ៊ឹមស៊ីវនណាស់អូនណាស់!!

ក:ចាំ គាត់បង្កើតអ្នកមីងហេ?

ខ:បងបង្កើតប៉ុន្តែដល់ពេលមានប្តីប្តីគេមិនអោយធ្វើអញ្ចឹងអញ្ចឹងថាអាក្រឹមអាក្រឹមអញ្ចឹងចុះ!!!
ពេលដែលគាត់ល្បីពេលអាក្រឹអាក្រឹមអីហ្នឹង!!!វាដើរទៅថតកុនបងរបស់ខ្ញុំអ្នកដែលផាត់មុខឱ្យ
ទេតើ!!!អម្ពរទេវីអីហ្នឹង!!!ប៉ុន្តែដល់ពេលមានប្តីប្តីគេអត់ឲ្យដើរអញ្ចឹងកាលពេលជំនាន់ហ្នឹងគេ
ហៅកូនស្ទឹមនោះ!!!ប្តីគេមិនឲ្យដើរនៅតែផ្ទះ!!

ក:បើសិនជាគាត់នៅដល់ឥឡូវធ្វើតារា។

ខ:បើនៅដល់ឥឡូវមិនបាច់ទេជាមួយហ៊ឹមស៊ីវន
ហ៊ឹមស៊ីវនអីនឹងដេកគ្រែតែពីរនាក់ណាស់ហើយនិងពិសិដ្ឋពីលីកា!!!3នាក់ពិសិដ្ឋពីលីកា
ហ៊ឹមស៊ីវនបងខ្ញុំនឹងគ្រែមួយតែ 3នាក់គ្នាគេទេណាស់!!
ហ្នំល្ខោនបាសាក់វៃខ្វសត៊ាន់កុំសាកជាមួយនឹងវា!!!

ក:បងស្រីរបស់អ្នកមីងហ្នឹងណាស់?

ខ:បងរបស់ខ្ញុំបង្កើតនិងណាស់!!

ក:គាត់ពូកែម្លេះ!!

ខ:គាត់ជំនាញខាងសិល្បៈឃីកេអីវ៉ាន់កំសត់វ៉ាឥឡូវហ្នឹង!!!

ក:ហ្នំ ប៉ុន្តែគាត់នៅរស់តើអ្នកមីង?

ខ:នៅរស់តើបើសិនជាឃីកេលក់មានតួនេះទេវាអត់មានតួអីទេ តួយាយផាន់។

ក:ហ៊ឺ តួកាច!!

ខ:តួយាយផាន់!!

ក:អ្នកមីងអត់មានរូបថតអត់មានរូបអ្វីរបស់គាត់នៅផ្ទះទេមីង?

ខ:មានប៉ុន្តែមិនដឹងនៅទីណាទេនេះ!!

ក:អត់អីទេអញ្ចឹងអ្នកមីង!!សុទ្ធតែអ្នកសិល្បៈដែរ!!

ខ:អ្នកសិល្បៈខាងច្រៀងប៉ុន្តែអត់មានគ្រូទេ!!!ឲ្យវារៀននេះចុះផ្ទង់ផ្តើមទៅប៉ុន្តែទីបំផុតដល់ពេលគេការគាត់វាមានប្តីក្រោយខ្ញុំទេតើ!!

ក:ចាំ!!!

ខ:ដល់ពេលគេការហើយប្តីរបស់គេអត់ឲ្យទៅអញ្ចឹងគេប្រចណ្ឌនោះ!!!!ហើយធម្មតាសិល្បយើងនៅជាមួយស្រីៗចេះតែចាប់ដៃចាប់ជើងនៅជាមួយប្រុសប្រុសផាត់មុខផាត់អ្វីឲ្យគេប្តីគេប្រច័ណ្ឌ!!

ក:ហ្នឹងហើយគាត់ជំនាញផាត់មុខដែរអ្នកមីង?

ខ:គាត់និយាយទៅគាត់ជំនាញខាងផាត់មុខទេតើ!!!
ថាជំនាញរបស់វាគ្រាន់បើជាងខ្ញុំផង!!!ព្រោះវាខាងសិល្បៈណាស់អញ្ចឹងច្រៀងក៏វាចេះវាយឃ្លសក៏វាចេះបាសាក់យីកេស្អីក៏វាចេះ ល្ខោនខោល យីកេគាត់ហ្នឹងនោះ!!! ចុះគាត់អ្នកសិល្បៈយើងនៅស្អាតចាស់ហ្នឹង!!

ក:គាត់ចូលរៀនអ្នកមីងនោះ?

ខ:ហ្នឹងហើយរៀននៅទីហ្នឹងប្រមាណប្រហែលបីឆ្នាំណាស់!!នៅតែមួយឆ្នាំទៀតចេញហើយណាស់!!

ក:គាត់ចិត្តរបស់គាត់ដុងតាំងពីតូចមកតែម្តងអ្នកមីង?

ខ:ខ្ញុំហើយនឹងម៉ែខ្ញុំផ្គួចអោយវាទៅខាងហ្នឹងតែម្តង!!ឲ្យមានមួយព្រោះនិស្ស័យខាងខ្សែខាងរបស់ខ្ញុំពីសង្គមចាស់មកគឺខាងសិល្បៈប៉ុន្តែគ្រាន់តែថាសិល្បៈហ្នឹងតារាចម្រៀងសម័យយើងអត់មានទេខាងបូរាណ!!!ឥលូវសាកអោយវាច្រៀងបើសិនជាមានខារ៉ាអូខេវាច្រៀងឡើងក្រលួច!!

ក:សុទ្ធតែមានខាងសិល្បៈអញ្ចឹងដែរហើយបើសិនជាគាត់លេងភ្លេងអ្វីក៏អត់ចេះទេតែចេះតែសម្តែង?

ខ:បានម៉ាអែម!!!!

ក:ទាំងលេងភ្លេងទាំងអ្វីទៀត?

ខ:ទាំង យីកេតវ៉ាន់ហ្នឹង!!អាស្នីសាខេ យីកេដេញបានមួយអែម!!!!

ក:ហើយគាត់មានបន្តវេនឲ្យកូនរបស់គាត់ក្រោយទៀតទេអ្នកមីង?

ខ:កូនក្រោយវាអត់មានជំនាញខាងអាហ្នឹងវាមានជំនាញខាងសម័យឆាច់ឆាច់ឆា!!!ខាងដើរលេងតវ៉ាន់វាជំនាញ!!!

ក:ហើយស្តាយដែលស្តាយជំនាញគាត់ដល់ពេលកប់ចោលត្រង់ហ្នឹង!!!

ខ:កប់ចោលចោលតែម្តង!!!!

ក:ហ្នឹងហើយគាត់អត់មានចិត្តចង់ជំនះចង់ចូលវិញអីទេ?

ខ:អត់ជំនះ តាមប្តីសុខចិត្តតាមប្តី។

ក:ឥឡូវគាត់នៅនេះ?

ខ:ឥឡូវធ្វើការរោងចក្រហើយ!!! ក:ហ៊ឺ!! ខ:ពេលមុនធ្វើការបុកគ្រឹះហើយឃើញធ្វើការអញ្ចឹងអញ្ចឹងខ្ញុំទាន់អោយទេតើ!!!!ខ្ញុំថានឹងហើយសុំមុខឯងអញថាកុំឈប់រៀនខ្លួនឯងឲ្យឯងទៅរៀនខាងនោះទៅអោយវាលោតមួយទៅណា!!ក:ចាំ!!!ខ:ទីបំផុតឯងអត់អញ្ចឹងទៅធ្វើការរោងចក្រអញ្ចឹងមួយចុះពី!!!!ដល់ឥឡូវឯងឈប់ធ្វើការរោងចក្រវាឈប់បុកគ្រឹះវិញ វាចូលរោងចក្រវិញ!!

ក:ហ៊ឺស្តាយណាស់អ្នកមីងស្តាយចំណេះរបស់គាត់ណាស់!!ចុះអ្នកមានពេលពីក្មេងមកធ្លាប់មានសង្ឃឹមចង់ថាគិតថាអនាគតរបស់ខ្លួនឯងមុខតែរីកចម្រើនជាងហ្នឹង?

ខ:នឹកឃើញអញ្ចឹងដែរអូនប៉ុន្តែឥឡូវទៅមុខវាមិនរួចទេវានៅត្រឹងត្រឹមហ្នឹងហើយ!!!ជួនកាលសង្ឃឹមរាល់ថ្ងៃក៏ស្រមៃដែរអូនរាល់ថ្ងៃនៅស្រមៃដែរមិនមែនថាអត់ទេមិនមែនថាតែពេលមុនទេរាល់ថ្ងៃស្រមៃប៉ុន្តែបានត្រឹមតែស្រមើស្រមៃ!!

ក:ចាំមីងធ្លាប់សង្ឃឹមថាពេលនៅតូចដូចថាធំឡើងចង់ធ្វើអ្វីមួយអី?

ខ:នឹកឃើញទេតើឥឡូវថាអញ្ចេកឥឡូវក៏ស្រមៃដែរមិនបាច់តែពីតូចទេប៉ុន្តែទៅមិនរួចគ្រាន់តែបានត្រឹមតែស្រមៃ!!!

ក:ចាំ!!

ខ:អាធាតុពិតវាអត់។

ក:ចាំហ្នឹងហើយធនធានយើងដូចថាតាមហ្នឹងអញ្ចឹងដែរអ្នកមីង!!!!ចុះអ្នកមីងដូចមានថាខ្ញុំចង់សួរអ្នកមីងចុងក្រោយបន្តិចថាមានពាក្យអ្វីក៏ចង់ផ្តាំផ្ញើទៅកូនកូនកូនចៅក្មួយរបស់អ្នកមីងជំនាន់ក្រោយអីទេ?

ខ:អត់មានអីទេគ្រាន់តែចង់និយាយទៅកូនរាល់ថ្ងៃថាកូនម៉ែវាធ្លាប់ឆ្លងកាត់ម៉ែវាពិបាកវេទនាហើយណាស់អញ្ចឹងម៉ែមានបន្តិចបន្តួចខ្មែរអត់មានអីចែកអោយកូនទេម៉ែមានតែអោយកូនទៅរៀនមានចំណេះកុំយកគំរូម៉ែកុំយកគំរូប៉ាព្រោះប៉ាសំណាង!!ណាស់អញ្ចឹងកូនឯងឲ្យដូរមុខសំណាងចេញ!!

ក:ចាំឲ្យលុបត្រឹមហ្នឹង!!!!

ខ:លុបអាសំណាង់នឹងចេញទៅព្រោះយើងរកចាប់ជំនាញណាដើម្បីដូចថាប្រាក់ខែបន្តិចបន្តួចឱ្យយ៉ាងម៉េចអោយវាស្រួលខ្លួនទៅចុះ!!!

ក:ហ្នឹងហើយកុំអោយហាត់ទេ!!

ខ:ហ្នឹងហើយកុំឱ្យគេថាឱ្យឪសំណាង់ហើយកូនឱ្យចៀសផុតពីសំណាង់!!!អញ្ចឹងយើងមិនមែនថាអោយយើងនេះទេយើងជា
ជៀសអោយផុតពីហ្នឹងទៅដើម្បីយកតម្រេះវិជ្ជាយើងនឹងធ្វើការងារណាអោយវាស្រណុកខ្លួនបន្តិចទៅម៉ែឆ្អែតចង់ដុតភ្លើងអាកោ
រៀនភ្លើងចង្រ្កានក៏ម៉ែធ្លាប់មានស្មាទោសនិយាយឲ្យអស់កេរ្តិ៍ទៅអូន!រាល់ថ្ងៃមួយឆាកជីវិតរបស់មីងពីដឹងក្តីមកដល់ចំណាស់នេះអោយតែធ្វើសំភឹងទេអូនមួយមុខទេក្រៅពីហ្នឹងមីងហែលអស់ហើយតាំងពីខ្ញុំគេតាំងពីស្អីខ្វេចខ្វីអត់សល់ទេ!!នៅតែថាលក់ខ្លួនមួយមុខមីងអត់ធ្លាប់!!និយាយមែនអាហ្នឹងចិបមួយអាហ្នឹងចោល 1ខែខ្ញុំគេក៏មីងធ្លាប់មួយខែ30000 ក៏មីងធ្លាប់បេនឡានសុរិយាយើងនិងរត់តុគុយទាវឲ្យគេអត់ហ៊ានរត់តុទេគេរៀនជាមួយគ្នា!!!!សុខចិត្តទៅអង្គុយលាងចាន!!1ខែតែ 4 ម៉ឺនទេ!!

ក:ចាំ!!!ដល់ពេលអុំទូកអត់មានលុយទៅចាយទៅខ្ចីលុយគេមុនទៅបើកប្រាក់ខែគេមុននាំម៉ែដើរលេង
ដល់ពេលចូលធ្វើការពួកម៉ាកទៅស៊ីបាយខ្ញុំរត់ពួននៅក្នុងបន្ទប់ទឹកនោះ!!!!ខ្មាស់គេ!!!គេសុទ្ធតែប៉េអឹមយើងរៀនជាមួយគ្នាទេប្រុសនោះ!!ក:ចាំ!! ខ:អញ្ចឹងគេប៉េអឹមគេចូលទៅ

យើងប៉េដែរប៉ុន្តែប៉េពូន!!!រត់ចូលក្នុងបន្ទប់ទឹក
វាឃើញយើងវាស្គាល់យើងណាស់!!!ហ្អែងចេញមកមិនបាច់ពូនអញទេអញដឹងហើយ!!!ញោះមឡើងញាក់សាច់ ស្មាទោសអាលើតូចក៏មិនចេញអាធំក៏មិនចេញវាភ័យណាស់យើងភ័យបត់ជើងទូចក៏អត់ចេញបត់ជើងធំក៏មិនចេញហើយពូនណាមិនពូន
ពូនចំបន្ទប់ទឹកពេលគេចូលបន្ទប់ទឹក
ហើយចុះគេរៀនជាមួយយើងគេសុទ្ធតែធ្វើការគ្រាន់បើៗបែរជាយើងរត់គុអូន!!!ញ៉ុមឆ្លងកាត់អស់ហើយមួយឆាកជីវិតញ៉ុមនៅតែលក់ខ្លួនមួយមុខទេបានខ្ញុំនិយាយប្រាប់ប្ដីចខ្ញុំថា
ចុះឯងរាល់ថ្ងៃមិនលក់ខ្លួនអោយខ្ញុំហេ!!!

ក:ហេម្យ៉ាង ទៅជាកំប្លែងវិញទៅ!!!

ខ:ដូចថាកំឡាៗយើងអញ្ចឹងទៅ!!!!:អ៊ីចឹងបានប្រាប់កូនខាងម្ដាយហៃលអស់ហើយ
ម៉ែមិនចង់ឲ្យកូនអញ្ចឹងទេ!!!!អញ្ចឹងកូនខំប្រឹងរៀនទៅណាស់!!!!ក:ចា៎!!!ខ:
ដើម្បីអនាគតម៉ែគ្មានអ្វីឲ្យមានតែតម្រិះឲ្យ!!មិនមែន អនាគត
ម៉ែឯណាអនាគតកូនឯងទេ!!!!កូនគេរៀនចេះដឹងមានប្រាក់ខែធ្វើធំដំក៏កូនឯងធ្វើនឹកឃើញថាកូនឯងមិនប្រាក់ខែ!!មួយខែ4 5
រៀលនិងជាសទ្ធារបស់កូនឯងទេ!!!ក:ចា៎!!ខ:ហើយខ្ញុំតាំងចិត្តអញ្ចឹងថាពីអ្នកនេះពេលធំទៅរៀនបានធំហើយវាមានមុខរបររកស៊ីហើយអូនណាស់មីងសុំសីលកាន់ធមិកាន់អារ្យហើយអូន!!!

ក:ហ៊ីទើបតែប៉ុណ្ណឹងសោះអ្នកមីង!!!

ខ:អត់ទេចង់និយាយថាអញ្ចេះមួយសីលទៅវត្តអញ្ចឹងទៅណាស់អូនណាស់!!! ក:ចា៎!!!
ខ:ឱកូនមានអនាគតមានអីអញ្ចឹងទៅណា!!!ហើយយើងទៅនៅវត្តអញ្ចឹងទៅវាហួសពេក!!!អញ្ចឹងយើងទៅរកធមិទៅរកអារ្យទៅ!!!!ព្រោះកូនមានអនាគតហើយហើយថ្ងៃណាថ្ងៃសីលកូនណានឹកឃើញអោយក៏ឱ្យមិនអោយជឿរឿងវាទៅ!!!!

ក:ចា៎!!!

ខ:មែនខ្ញុំតាំងចិត្តអញ្ចឹង!!!ដូចផ្ទះនេះផ្ទះនេះគឺកេរ្តិ៍ខាងប្ដីទេ!!!អញ្ចឹងបានថាក៏ខ្ញុំអត់ទាមទារដែរឲ្យតែខ្លួនបានធំធំ មានអ្នកណាទៀតមានទៅអោយទុកផ្ទះនេះឲ្យកូន!!!

ក:ចា៎!!

ខ:ខ្ញុំច្រើននិយាយតែអញ្ចឹងបើឯងមានអ្នកណាគេទៀតឯងទៅចុះ!!
តិចគេទៅមែនតិចទឹកភ្នែកចុះ!!!នឹងខ្ញុំអត់ដឹងទេថាឯងទៅយកមីហ្នឹងខ្ញុំទឹកភ្នែកអ្វីទៀតបានដឹងថាប្តីទៅហើយនឹង!!!តែផ្ទះទុកឲ្យកូន!!!

ក:បើគេលែងស្រណោះយើងហើយ!!!

ខ:គេលែងស្រណោះយើងហើយហ្នឹង គេក្មេងយើងចាស់ចាំអង្កាល់ចាំរគេស្រណោះ!!!

ក:ដល់ហើយមីងដូច ប្រវត្តិអ្នកមីងមានច្រើនណាស់ មីងថាបីថ្ងៃអត់អស់ផង!!!!

ខ:3ថ្ងៃអត់អស់ផង!!!!

ក:អ្នកមីងអរគុណច្រើនដែលបានអោយខ្ញុំមកសម្ភាសន៍!!!

ខ:អត់អីទេ!!!

ក:សំរាប់មីងនៅក្នុងថ្ងៃហ្នឹងហើយការសម្ភាសន៍នេះត្រូវបានដាក់បញ្ចូលក្នុងវេបសាយរបស់សាកលវិទ្យាល័យ ប៊ី វ៉ាយ យូនៅសហរដ្ឋអាមេរិកអ្នកមីងណាស់ហើយសូមអរគុណមីងច្រើន។